# បឋមវិបស្សនា វិបស្សនា
# កម្មដ្ឋាន




ប្រាសាទវេស្សវណ្ណស្សគធាវុធំ

ភូមិរលួស ឃុំបឹងទូក ស្រុកទឹកឈូរ ខេត្តកំពត

ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉េម យានិកត្ថេរ

រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនី បុណ្ណធម្មោ

លោក ហាស់ ម៉េងហួត

# សព្វទានំ ធម្មទានំ ជិនាតិ
# ធម្មទានឈ្នះអស់ទានទាំងពួង



ឧបត្ថម្ភធម្មទានដោយ : ឯកឧត្តម ហាស់ វ៉ារី

ទីប្រឹក្សារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

និង លោកជំទាវ តាំង ស៊ូអេង ព្រមទាំងបុត្រ និង ចៅ

សូមឲ្យបានជាបច្ច័យដល់ព្រះនិព្វាន

# អារម្ភកថា

ដោយមានការលំបាកយ៉ាងខ្លាំង ក្នុងការសិក្សារបស់សមណៈ ឧបាសក ឧបាសិកា ដែលសិក្សានូវ វិបស្សនា និង កម្មដ្ឋាន មូលហេតុកង្វះខាតនូវឯកសារ ។ ខ្ញុំព្រះករុណា អាត្មាភាពក៏បាន ប្រមែប្រមូលចងក្រងនូវ ឯកសារវិបស្សនា និង កម្មដ្ឋាននេះឡើង ដើម្បីអោយងាយស្រួលក្នុងការសិក្សា ។ សៀវភៅវិបស្សនា និង កម្មដ្ឋាននេះ រួមមានគោលធម៌ បឋមវិបស្សនា និង វិបស្សនាកម្មដ្ឋាន ដែលខ្ញុំព្រះករុណា អាត្មាភាព នឹង ធ្វើការបោះពុម្ពផ្សាយជាបន្តបន្ទាប់ និង ឈានទៅបោះពុម្ពផ្សាយនូវសៀវភៅ " អានាគតទសវង្ស របស់ព្រះពុទ្ធ " ជាបន្តទៅទៀត ។ ដោយមានការ ឧបត្ថម្ភដ៏ធំធេងរបស់ ឯកឧត្តម ហាស់ ម៉ារី ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង លោកជំទាវ នាំង ស៊ូអេង ខ្ញុំព្រះករុណាអាត្មាភាព ក៏ដំណើរការ បោះពុម្ពផ្សាយនេះបានល្អប្រសើរ ។

« ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យាតិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនទី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត »

ជាទីបញ្ចប់ ដោយគុណានុភាពនៃធម្មទាននេះ សូមអោយសព្វសត្វទាំងអស់នៅក្នុងសំសារវដ្ត បានពើបប្រទះនូវធម៌ដ៏ប្រសើរក្រៃលែង រួចចាកផុតទុក្ខ និងបានសំរេចនូវលោកុត្តរធម៌ កុំបីខានឡើយ ។

ថ្ងៃទី ១៥ ខែ ០៩ ឆ្នាំ ២០១០ ពស. ២៥៥៤

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យាទិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

# ពុទ្ធរតនប្បណាម

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

( សូត្រ ៣ ដង )

ប្រែថា: វីកិរិយានមស្សការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្ត ដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅ ព្រះអង្គឡើយ ។

( ក្រាបថ្វាយបង្គំម្តង)

# ថ្វាយបង្គំព្រះពុទ្ធរតនៈ

យោ សន្និសិន្នោ វរពោធិមូលេ មារំ សសេនំ មហតឹ វិជេយ្យោ សម្ពោធិមាគច្ឆិ អនន្តញាណោ លោកុត្តមោ តំ បណមាមិ ពុទ្ធំ ។

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យាទិកត្ថេរ, រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ, លោក ហាស់ ម៉េងហួត )

ប្រែថា ៖ ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចំរើននូវព្រះអានាបានស្សតិកម្មដ្ឋានលើរតនបល្ល័ង្គ ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មានព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធ អង្គនោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ៕

ប្រែថា ៖ ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ ជាព្រះពុទ្ធក្នុងកាល

ខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្ទកល្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធ ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

## បង្អោនកាយវាចាហើយតាំងចិត្តរលឹកដល់

## ព្រះពុទ្ធគុណ ទាំង ១០ ព្រះនាម

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ប្រែថា : ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគនិងវចីបយោគ ! សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួង

ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូ អាចារ្យណាប្រដៅព្រះអង្គឡើយ វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គ បរិបូរណ៍ដោយ វិជ្ជា៣ និង វិជ្ជា៨ និង ចរណៈ ១៥ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវ ត្រៃលោក អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយ សីលាទិគុណ រកបុគ្គលណាមួយ ស្មើគ្មាន បុរិសទម្មសារថិ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នក ទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន សត្ថា ទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវ ចតុរារិយសច្ចៈ ហើយញ៉ាំង អ្នកដទៃឱ្យត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាមថា

ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ ត្រៃភព ខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើត ទៀតឡើយ ។

( ក្រាបថ្វាយបង្គំម្តង )

## ប្រកាសបេ្តជ្ញាខ្លួនដោយពាក្យសច្ចៈថា:

នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ៕

ប្រែថា : នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ ពុទ្ធោ មេ សរណំ វរំ មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរលឹក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជ័យមង្គល ចូរមានដល់ ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

( ក្រាបថ្វាយបង្គំម្តង )

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ ឃែម យាតិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

# សូមខមាទោសចំពោះព្រះពុទ្ធជាម្ចាស់ថាៈ

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។

ប្រែថា : ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធ ដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈ ដ៏ឧត្តមគឺត្បូង ពុទ្ធេ យោ ខលិតោ ទោសោ ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់ ពុទ្ធោ ខមតុ តំ មមំ សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោស នោះ ដល់ខ្ញុំព្រះករុណា។

( ក្រាបថ្វាយបង្គំម្តង)

# ថ្វាយបង្គំព្រះធម្មរតនៈ

អដ្ឋង្គិការិយបថោ ជនានំ មោក្ខប្បវេសាយ ឧជូ ច មគ្គោ ធម្មោ អយំ សន្តិករោ បណីតោ និយ្យានិកោ តំ បណមាមិ ធម្មំ ។

ប្រែថា : ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ប្រការជាគន្លងដំណើរនៃព្រះអរិយបុគ្គល ជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយា ញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យ ត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្ម នោះដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង)

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យានិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ៕

ប្រែថា : ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមក ក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាល ទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

## បង្អោនកាយវាចា

## ហើយតាំងចិត្តរលឹកដល់ធម្មគុណថា

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ៕

ប្រែថា : ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ ( ធម្មោ ព្រះនព្វលោកុត្តរធម៌មាន ៩ប្រការ គឺៈ មគ្គ ៤ ផល ៤ និព្វាន ១) សន្ទិដ្ឋិកោ ជាធម៌ដែលព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង អកាលិកោ ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើ ព្រះអរិយមគ្គកើតឡើងហើយព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ ឯហិបស្សិកោ ជាធម៌គួរដល់ ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គល ដែលបានសម្រេច មគ្គផលហើយក៏គួរនឹងហៅបុគ្គលដទៃឱ្យចូលមក មើលបាន ឱបនយិកោ ជាធម៌ដែលព្រះអរិយបុគ្គល បង្អោនចូលមកទុក ក្នុងខ្លួនដោយអំណាចនៃភាវនា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ

ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមាន ឧត្តមជិតញ្ញបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

( ក្រាបថ្វាយបង្គំម្តង)

## ប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា

នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។

ប្រែថា : នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណា មិនមានឡើយ ធម្មោ មេ សរណំវរំ មានតែព្រះធម៌ជាម្ចាស់ ជាទីពឹងទីរលឹក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជ័យមង្គលចូលមានដល់ ខ្ញុំព្រះករុណា ដោយកិរិយា ពោលនូវពាក្យសច្ចៈនេះ ។

( ក្រាបថ្វាយបង្គំម្តង)

# សូមខមាទោសចំពោះព្រះធម៌ជាម្ចាស់ថា៖

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ៕

ប្រែថា : ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរ ប្រការគឺ ព្រះបរិយត្តិធម៌ និង ព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង ធម្មេ យោ ខលិតោ ទោសោ ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ ហើយ ក្នុងព្រះធម៌ជាម្ចាស់ ធម្មោ ខមតុ តំ មមំ សូមព្រះធម៌ជាម្ចាស់អត់នូវទោស នោះ ដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង)

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ ឃុន យ៉ែម យាទិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ ឃុន ប៊ុនធី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

# ថ្វាយបង្គំព្រះសង្ឃរតនៈ

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ សព្វមលប្បហីនោ គុណេហិនេកេហិ សមិទ្ធិបត្តោ អនាសវោ តំ បណមាមិ សង្ឃំ ។

ប្រែថា: ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រីយ៍រម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួង បន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយ នូវកិរិយាសម្រេចដោយគុណទាំងឡាយ ដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព។

(ក្រាបថ្វាយបង្គំម្តង)

យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ៘

ប្រែថា : ព្រះសង្ឃទាំងឡាយឯណា ដែលជា ព្រះសង្ឃបានសម្រេច មគ្គ និង ផល កន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ នឹងបាន សម្រេច មគ្គ និង ផល ក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេច មគ្គ និង ផល ក្នុងកាលជា បច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

## បង្អោនកាយវាចា

## ហើយតាំងចិត្តរលឹកដល់សង្ឃគុណថា:

សុបដិបន្នោ ភគវតោ សាវកសង្ឃោ

ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ

ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯសភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

ប្រែថា : សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺ ប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺ ប្រតិបត្តិជា មជ្ឈិមបដិបទា ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មាន ព្រះភាគ លោកប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្សេម ផុតចាកទុក្ខទាំងពួង សាមីចិបដិបន្នោ ភគវតោ

**សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សម គួរដល់ **សាមីចិកម** គឺប្រតិបត្តិគួរដល់ សីល សមាធិបញ្ញា **យទិទំ ចត្តារិបុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន៤គូ គឺ ព្រះសង្ឃដែលបានសម្រេច នូវ សោតាបត្តិមគ្គ និង សោតាបត្តិផល ជាគូ ១. សកទាគាមិមគ្គ និង សកទាគាមិផល ជាគូ ១. អនាគាមិមគ្គ និង អនាគាមិផល ជាគូ ១ អរហត្តមគ្គ និង អរហត្តផល ជាគូ ១. **អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបានសម្រេចនូវ សោតាបត្តិមគ្គ ១. សោតាបត្តិផល ១. សកទាគាមិមគ្គ ១. សកទាគាមិផល ១. អនាគាមិមគ្គ ១. អនាគាមិផល ១. អរហត្តមគ្គ១ អរហត្តផល ១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវ័ក នៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គល

ឧទ្ទិសចំពោះ អ្នកមានសីល ហើយនាំមកអំពីចម្ងាយ បង្អោនចូលមកបូជា អាហុនេយ្យោ លោកគួរទទួលនូវ អាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និង មិត្ត ដែលមកអំពីទិសផ្សេងៗហើយបង្អោនចូលមកបូជា ទក្ខិណេយ្យោ លោកគួរទទួលនូវទានដែលបុគ្គលជឿនូវ កម្មនិងផលនៃកម្មហើយបូជា អញ្ជលិករណីយោ លោកគួរ ដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញក្ខេត្តំលោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែង ជាងគ្មាន។

(ក្រាបថ្វាយបង្គំម្តង)

## រលឹកដល់សង្ឃគុណដូច្នេះរួចហើយ
## គប្បីប្រកាសបញ្ជ្រាខ្លួន ដោយពាក្យសច្ចៈថា:

នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។

ប្រែថា : នត្ថិ មេ សរណំ អញ្ញំ វត្ថុដ៏ទៃ ជាទីពឹងទីរលឹក នៃខ្ញុំព្រះករុណាមិនមានឡើយ សង្ឃោ មេ សរណំ វរំ មានតែព្រះសង្ឃជាម្ចាស់ជាទីពឹងទីរលឹក ដ៏ប្រសើរ របស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេជយមង្គលំ សូមសិរីសួស្តី ជយមង្គលចូរមានដល់ ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវ ពាក្យសច្ចៈនេះ ។

(ក្រាបថ្វាយបង្គំម្តង)

## ប្តេជ្ញាខ្លួនដូច្នេះរួចហើយ
## គប្បីសូត្រសូមខមាទោសនឹងព្រះសង្ឃថា

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ ។

ប្រែថា : ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសង្ឃ ដ៏ប្រសើរមានពីរប្រការ គឺ សម្មតិសង្ឃ និង អរិយសង្ឃ ដោយអវយវៈ ដ៏ឧត្តមគឺត្បូង សង្ឃេ យោ ខលិតោ

ទោសោ ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់ សង្ឃោ ខមតុ តំ មមំ សូម ព្រះសង្ឃ ជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា។

(ក្រាបថ្វាយបង្គំម្តង)

## បណាមគាថា

យោ កប្បកោដីហិបិ អប្បមេយ្យំ កាលំ ករោន្តោ អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ នមោ មហាការុណិកស្ស តស្ស ។

.ព្រះលោកនាថអង្គឯណា ទ្រង់ធ្វើនូវកម្មដែលសត្វលោក ធ្វើបានដោយលំបាក អស់កាលរាប់ប្រមាណមិនបាន សូម្បីដោយ កោដិកប្ប ទ្រង់ដល់នូវសេចក្តីលំបាក ដើម្បីប្រយោជន៍ ដល់សត្វ លោក ខ្ញុំសូមនមស្ការ ដល់ព្រះលោកនាថអង្គនោះ ទ្រង់ប្រកប ដោយ មហាករុណាគុណ ។

ព្រះពុទ្ធជាទីពឹង ជាពុំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ។

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ ម៉ែម យាទិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន។
ធ្វើកម្មជាកម្រ មនុស្សនិករត្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វនោះ ជាទីពឹងសព្វកាល ។

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ ជីវលោកោ នមោ អវិជ្ជាទិកិលេសជាលំ វិទ្ធំសិនោ ធម្មវរស្ស តស្ស ។**

**.សត្វលោកតែងអន្ទោលទៅកាន់ភពតូច និងភពធំ ព្រោះមិនដឹងនូវធម៌ ដ៏ប្រសើរឯណា ដែលព្រះពុទ្ធទ្រង់សេពជានិច្ច ខ្ញុំសូមនមស្ការដល់ព្រះធម៌ដ៏ប្រសើរ ជាគុណមានកិរិយាកំចាត់បង់នូវបណ្តាញគឺកិលេស មាន អវិជ្ជាជាដើមនោះ។**

សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កម្មជាគោល
ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ

ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
ព្រះពុទ្ធដ៏ឧត្ដម ចិត្តខ្ញុំសូមនមស្ការ
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់អវិជ្ជា គឺបណ្ដេញកិលេសហើយ ។

**គុណេហិ យោ សីលសមាធិបញ្ញា វិមុត្តិញ្ញាណប្បភូតីហិ យុត្តោ ខេត្តព្ភានាំ កុសលត្ថិកានំ តមរិយសង្ឃំ សិរសា នមាមិ ៕**

**.ព្រះអរិយសង្ឃឯណា អ្នកប្រកបដោយគុណទាំងឡាយ មានសីលសមាធិបញ្ញា និង វិមុត្តិញ្ញាណជាគោល ខ្ញុំសូមនមស្ការនូវព្រះអរិយសង្ឃនោះដោយសិរសា លោកជាស្រែបុណ្យរបស់ពួកជនអ្នកមានសេចក្ដីត្រូវការ ដោយកុសល ។**

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យានិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ។

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ**
**សារីរិកធាតុ មហាពោធឹ ពុទ្ធរូបំ សកលំ សទា ។**

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី រិកធាតុនៃព្រះពុទ្ធ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលស្ថិតនៅគ្រប់ទី ស្ថាន នានានោះទាំងអស់ ។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្រ។
សូមទាន់ព្រះអរិ- -យមេត្រីថ្ងៃវិសិដ្ឋ

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ ង៉ែម យានិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហុត )

សូមបានឃើញធម៌ពិត          សមដូចចិត្តប្រាថ្នាហោង។

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ
រតនត្តយំ យំ បុញ្ញាភិសន្ទំ វិបុលំអលត្ថំ តស្សា
នុភាវេន ហតន្តរាយោ ៗ

ខ្ញុំសូមនមស្ការ          លើកហត្ថាឱនសិរសី
បង្គំគុណទាំង៣          ខ្ពស់លើសលប់ត្រៃលោកា។
សូមបុណ្យកងកុសល          ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា          ដូចជលសាធំទូលាយ ។
សូមឱ្យកំចាត់បង់          អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ          ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព          បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន          សូមបានក្សាន្តកុំមានមោះ។
ដោយគុណនមស្ការ          ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ          ដាក់ដល់ឋាននិព្វានហោង។

# សមថកម្មដ្ឋាន និង វិបស្សនាកម្មដ្ឋាន

## ថ្នាក់បឋម

## កម្មវិធីសិក្សា ដូចខាងក្រោមនេះ

## ត្រៃសរណគមន៍ សម្រេចដោយសទ្ធា

១. សីល ៥ ‿ ៨ ‿ ១០ របស់ឧបាសក ឧបាសិកា និងកម្មបថ ៨០ និង សីល ១០ របស់សាមណេរ សីល ៤ របស់ភិក្ខុ សម្រេចដោយ ចេតនា ចេតសិក សំវរៈ អវីតិក្កមៈ ។

២. អានាបានស្សតិ "ខ្យល់ ៤ ត្រកូល" និង កម្មដ្ឋាន ១០មាន ពុទ្ធានុស្សតិ ជាដើម ដែលមានអានុភាព ឱ្យសម្រេចត្រឹមគុណធម៌ គឺ : ឧបចារជ្ឈាន និង ឧបចារជ្ឈាន ដែលជាបុព្វភាគនៃអប្បនា ក្នុងកម្មដ្ឋាន ២៦ មាន បឋវី កសិណ ជាដើម ។

៣. ការពង្រឹង ឧបេក្ខាចិត្ត ដោយវសីទាំង ៥ ។

‹ ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ ថៃម យាទិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនវី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត ›

៤. ការកំណត់ដឹងនូវ រូបបរមត្ថ និង នាមបរមត្ថ តាមឆទ្វារ "ទ្វារ ៦" ចំពោះរូប និង នាមជំពូកខ្លះ មាន សុទ្ធដ្ឋក រូបជាធំ ។

៥. ការកំណត់ដឹងនូវបច្ច័យនៃនាម និងរូប ប្រព្រឹត្តទៅតាមកាលទាំង ៣ ។

៦. ការកំណត់ដឹងនូវត្រៃលក្ខណ៍ ។

៧. ការលះបង់នូវ វិបស្សនូបក្កិលេស ១០ ដោយត្រៃលក្ខណ៍។

៨. ការបាននូវ អនុបស្សនា ៧ មាន អនិច្ចានុបស្សនាជាដើម ។

# សិក្សាអំពីកិលេស និង ធម៌

១. កិលេសគ្រោតគ្រាត ទុច្ចរិត១០ ។

២. នីវរណៈធម៌ ៥ ។

៣. កិលេស៣ គឺៈ លោភៈ១ ទោសៈ១ មោហៈ១
បាំងត្រៃលក្ខណ៍ គឺៈ អនិច្ចំ១ ទុក្ខំ១ អនត្តា១

៤. ធម៌ ៧ ជាបដិបក្ខ និង ធម៌ ៧ ។

៥. បញ្ញា ៣ ជាលោកិយ មាន ញាតបរិញ្ញាជាដើម ដែល
ព្រះយោគីត្រូវដឹង ។

# គោលធម៌មានចំនួន ៩

## ១. ត្រៃសរណគមន៍

វត្ថុជាទីពឹង ទីរលឹក មាន ៣ យ៉ាងគឺ : **ព្រះពុទ្ធ១ ព្រះធម៌១** និង **ព្រះសង្ឃ១** ។

១. លោកអ្នកប្រដៅពួកជន អោយប្រតិបត្តិល្អ ដោយ កាយ វាចា ចិត្ត តាមធម៌វិន័យ ហៅថា **ព្រះពុទ្ធ** ។

២. ធម៌វិន័យពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ហៅថា **ព្រះធម៌** ។

៣. ពួកជន ដែលបានស្តាប់ ពាក្យប្រៀនប្រដៅរបស់ ព្រះពុទ្ធ ហើយបួសប្រតិបត្តិល្អ តាមព្រះធម៌វិន័យ ហៅថា **ព្រះសង្ឃ** ។

# ត្រៃសរណគមន៍ សម្រេចដោយសទ្ធា

**សទ្ធា** : មានន័យថា ការជឿ ឬជំនឿមាន ៤យ៉ាងគឺ:

១. កម្មស្សទ្ធា ការជឿអំពើល្អ អាក្រក់ ។

២. វិបាកសទ្ធា ការជឿផលនៃ កម្ម ។

៣. កម្មស្សកតាសទ្ធា កាជឿអំពើដែលខ្លួនធ្វើ ហើយជាអំពើរបស់ខ្លួនឯងតែម្យ៉ាង ។

៤. តថាគតពោធិសទ្ធា ការជឿសេចក្តីត្រាស់ដឹង របស់ព្រះតថាគត ។

## ២. សីលៈ

**សីល** តាមលំដាប់ថ្នាក់ ដូច្នេះគឺ :

១. សីលរបស់ ឧបាសក ឧបាសិកាមាននិច្ចសីល គឺសីល៥ ឧបោសថសីល គឺសីល៨ អតិរេកសីល គឺសីល១០ និង កម្មបថ៨០ គឺកុសលកម្មបថ៤០ និង អកុសលកម្មបថ៤០ ។

(មានក្នុងសីលកថាសង្ខេប)

២. សីលរបស់សាមណេរ បានដល់សីល ១០ ។

( មានក្នុង សាមណេរវិន័យ)

៣. សីលរបស់ភិក្ខុ គឺសីល ៤ ។

( មានក្នុង ចតុប្បារិសុទ្ធិសីល)

## សីលសម្រេចដោយធម៌ ៤យ៉ាង គឺ

១. ចេតនា គឺ វិរតិចេតនា ,

២. ចេតសិក គឺ វិរតិចេតសិក ,

៣. សំវរៈ គឺ ការសង្រួម ៥យ៉ាង ,

៤. អវីតិក្កមៈ គឺ មិនប្រព្រឹត្តកន្លង ,

( មានក្នុងសីលកថាសង្ខេប) ។

# ៣. អានាបានស្សតិ

ការរំលឹកដង្ហើមចេញ ចូល ហៅថា អានាបានស្សតិ បានដល់ខ្យល់ ៤ត្រកូល :

១: កាល ដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ឯកាលដកដង្ហើម ចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង ។

២: កាល ដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី ឯកាលដកដង្ហើម ចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី ។

៣: អាត្មាអញនឹងជាអ្នកដឹងច្បាស់ នូវកាយ គឺ ដកដង្ហើមចេញទាំងអស់អោយប្រាកដ ទើបដកដង្ហើមចេញ ,អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវកាយ គឺ ដកដង្ហើមចូលទាំងអស់ អោយប្រាកដ ទើបដកដង្ហើមចូល ។

៤: អាត្មាអញ នឹងជាអ្នករំងាប់នូវកាយសង្ខារ គឺ ដកដង្ហើមចេញ ទើបដកដង្ហើមចេញ អាត្មាអញ នឹង ជាអ្នករំងាប់នូវកាយសង្ខារ គឺ ដកដង្ហើមចូល ទើបដកដង្ហើមចូល ។

## កម្មដ្ឋាន ១០ ដែលអោយសំរេចត្រឹម ឧបចារជ្ឈាន នោះគឺៈ

ពុទ្ធានុស្សតិ ១, ធម្មានុស្សតិ ១,

សង្ឃានុស្សតិ ១, សីលានុស្សតិ ១,

ចាគានុស្សតិ ១, ទេវតានុស្សតិ ១,

មរណានុស្សតិ ១, ឧបសមានុស្សតិ ១,

អាហារេបដិកូលសញ្ញា ១, និង ចតុធាតុវវដ្ឋាន ១។

ឧបចារជ្ឈាន ជាចំណែកខាងដើមនៃកម្មដ្ឋាន ២៦នោះគឺៈ

កសិណ ១០ , អសុភ ១០ , កាយគតាសតិ១,

អានាបានស្សតិ ១, និង ព្រហ្មវិហារ៤ ។

( មានក្នុង កម្មដ្ឋាននិទ្ទេស)

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ ឃូ យ៉ែម យាឥកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ ឃូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

# ៤. ការពង្រឹងឧបេក្ខាចិត្ត

▫

ឧបេក្ខាចិត្ត គឺ ចិត្តប្រព្រឹត្តទៅកណ្តាល ស្មើៗ ព្រងើយកន្តើយ តាមទ្វារចំពោះអារម្មណ៍ ។

ឧបេក្ខាចិត្ត ចាស់ក្លារឹងមាំទៅបានដោយសារ ការហាត់បង្វឹកដោយ វសី ( ការស្ទាត់ ) ទាំង ៥គឺ :

១: ស្ទាត់ក្នុងការ នឹករកអង្គឈាន ,

២: ស្ទាត់ក្នុងការ ចូលកាន់ឈាន ,

៣: ស្ទាត់ក្នុងការ តម្កល់ឈានទុក ,

៤: ស្ទាត់ក្នុងការ ចេញចាកឈាន ,

៥: ស្ទាត់ក្នុងការ ពិចារណាលះបង់អង្គឈាន ,

( មានក្នុង សីលកថាសង្ខេប ) ។

## ៥. ការកំណត់ដឹងនូវរូបបរមត្ថ និង នាម

បរមត្ថ តាមទ្វារ ៦ ចំពោះអារម្មណ៍ ៦ ដោយយក សុទ្ធដ្ឋករូប ជាធំ ។ សុទ្ធដ្ឋករូប (រូបពួក ៨ សុទ្ធ)គឺ:

១: បឋវីធាតុ ធាតុដី មានលក្ខណៈរឹង ។

២: អាបោធាតុ ធាតុទឹក មានលក្ខណៈ រាវជ្រាបសើម ។

៣: តេជោធាតុ ធាតុភ្លើង មានលក្ខណៈក្តៅ ។

៤: វាយោធាតុ ធាតុខ្យល់ មានលក្ខណៈល្ហើយៗ ។

៥: វណ្ណោ រូបពណ៌ មានការផ្ទប់នឹងចក្ខុបសាទជាលក្ខណៈ ។

៦: គន្ធោ ក្លិន មានការផ្ទប់នឹងឃានបសាទ ជាលក្ខណៈ ។

៧: រសោ រសជាតិ មានការផ្ទប់នឹងជិវ្ហាបសាទជាលក្ខណៈ ។

៨: ឱជា មានឱជជាលក្ខណៈ និង សិក្សាបន្ថែម សទ្ទរូប គឺ សំឡេង មានការផ្ទប់ និង សោតបសាទជាលក្ខណៈ ថែមទៀត ជាគំរប់ ៨ ។

# ទ្វារ ៦ គឺ :

ចក្ខុទ្វារ១ សោតទ្វារ១ ឃានទ្វារ១ ជិវ្ហាទ្វារ១ កាយទ្វារ១ និង មនោទ្វារ១ ។

( មានក្នុង សីលកថាសង្ខេប)

# អារម្មណ៍ ៦ គឺ :

រូបារម្មណ៍១, សទ្ទារម្មណ៍១, គន្ធារម្មណ៍១, រសារម្មណ៍១, ផោដ្ឋព្វារម្មណ៍១, ធម្មារម្មណ៍១ ។

( មានក្នុង សីលកថាសង្ខេប)

# ចិត្តចេតសិក កើតតាមទ្វារ ៦ គឺ :

| | | |
|---|---|---|
| **ចិត្តចេតសិក** | កើតតាម | **ចក្ខុទ្វារ១** |
| **ចិត្តចេតសិក** | កើតតាម | **សោតទ្វារ១** |
| **ចិត្តចេតសិក** | កើតតាម | **ឃានទ្វារ១** |
| **ចិត្តចេតសិក** | កើតតាម | **ជិវ្ហាទ្វារ១** |

ចិត្តចេតសិក កើតតាម កាយទ្វារ១

ចិត្តចេតសិក កើតតាម មនោទ្វារ១

ចិត្តចេតសិក ដែលកាន់យក រូបបរមត្ថ

ជាអារម្មណ៍ មាន ៥ យ៉ាងគឺៈ វិញ្ញាណ១. ផស្សៈ១. វេទនា១. សញ្ញា១. ចេតនា១. ។

វិញ្ញាណ : ធម្មជាតិដឹងនូវអារម្មណ៍ មានកិរិយាដឹងជាលក្ខណ។

ផស្សៈ : ធម្មជាតិប៉ះនូវអារម្មណ៍ មានកិរិយាប៉ះជាលក្ខណ ។

វេទនា : ធម្មជាតិសោយនូវអារម្មណ៍ មានកិរិយាសោយ ជាលក្ខណៈ ។

សញ្ញា : ធម្មជាតិចាំនូវអារម្មណ៍មានកិរិយាចាំជាលក្ខណៈ។

ចេតនា : ធម្មជាតិគិតនៅអារម្មណ៍មានកិរិយាគិតជា លក្ខណៈ

ពួកធម៌នេះហៅថា ធម៌ មានផស្សៈ ជាគំរប់ ៥

រូប ប៉ះនឹង ចក្ខុ , សទ្ទៈ ប៉ះនឹង សោតៈ,

គន្ធៈ ប៉ះនឹង ឃានៈ , រសៈ ប៉ះនឹង ជិវ្ហា,

ផោដ្ឋព្វៈ បានដល់ បឋវីធាតុ ១, តេជោធាតុ ១,

វាយោធាតុ ១, ជា៣រូប មកប៉ះនឹងកាយ ធម៌ បានដល់

អាបោធាតុ ១ , ឱជា ១ ,៦ មកប៉ះដល់ផ្លូវចិត្ត ។

# ការកំណត់ដឹងនូវរូបធម៌និងនាមធម៌

រូប (វណ្ណៈ) មកប៉ះផ្ទប់នឹងចក្ខុជារូប(១)ធម៌, ធម៌មានផស្សៈ(២) ជាគំរប់៥ កំណត់ដឹងនូវរូបនោះជានាម(៣)ធម៌ ។

សទ្ទៈ   សំលេងមកប៉ះផ្ទប់ និងសោតៈជារូបធម៌ , ធម៌មានផស្សៈជាគំរប់៥ កំណត់ដឹងនូវសំលេងនោះជានាមធម៌ ។

គន្ធៈ   ក្លិនមកប៉ះផ្ទប់នឹង ឃានៈ ។ល។

រសៈ   រសជាតិ មកប៉ះផ្ទប់នឹងជីវ្ហា ។ល។

ផោដ្ឋព្វៈ   មកប៉ះផ្ទប់នឹងកាយ ។ល។

ធម៌ (អាបោ-ឱជៈ)   មកប្រាកដដល់ផ្លូវចិត្ត   ជារូបធម៌. ធម៌មានផស្សៈជាគំរប់៥ កំណត់ដឹងនូវធម៌នោះជានាមធម៌ ។

---

(១) : បញ្ញាជាអ្នក កំណត់ដឹង ។

(២)និង(៣) : ពួកធម៌ មានផស្សៈជាគំរប់៥នេះ កើតឡើងដោយអំណាច នៃបញ្ញា ។

# ៦. ការកំណត់ដឹង នូវ បច្ច័យរបស់

# នាម និង រូបៈ

### ហេតុបច្ច័យ របស់រូបមាន ៥ គឺៈ

១. អវិជ្ជា មិនដឹង ,

២. តណ្ហា សេចក្តីប្រាថ្នា ,

៣. ឧបាទាន សេចក្តីប្រកាន់មាំ ,

៤. កម្ម អំពើល្អ និង អាក្រក់ ,

៥. អាហារ កវឡិង្ការាហារ ,

អវិជ្ជា១. តណ្ហា១. ឧបាទាន១. កម្ម ជាហេតុ អាហារ១ ជាបច្ច័យ ។

## បច្ច័យរបស់នាម

ចក្ខុវិញ្ញាណ : កើតឡើងព្រោះអាស្រ័យចក្ខុនិងរូប ។

សោតវិញ្ញាណ :កើតឡើងព្រោះអាស្រ័យ សោតៈនិងសទ្ទៈ។

ឃានវិញ្ញាណ :កើតឡើងព្រោះអាស្រ័យ ឃានៈនិងគន្ធៈ។

ជិវ្ហាវិញ្ញាណ ៖ កើតឡើងព្រោះអាស្រ័យ ជិវ្ហា និង រស ។

កាយវិញ្ញាណ ៖ កើតឡើងព្រោះអាស្រ័យ កាយនិងផោដ្ឋព្វ ។

មនោវិញ្ញាណ ៖ កើតឡើងព្រោះអាស្រ័យ ចិត្ត និងធម៌ ។

## នាម និង រូប ប្រព្រឹត្តទៅក្នុងកាលទាំង ៣ គឺ៖

អតីតកាល (ជាតិមុន) បច្ចុប្បន្នកាល (ជាតិឥឡូវនេះ)និង អនាគតកាល (ជាតិក្រោយ) បានព្រោះអាស្រ័យហេតុបច្ច័យ កាលបើហេតុបច្ច័យរលត់ហើយ នាមនិងរូប ក៏រលត់ដែរ ។

## ៧. ត្រៃលក្ខណ៍ធម៌ ៖

១. អនិច្ចំ ប្រែថា អស់ទៅ ,

២. ទុក្ខំ ប្រែថា បៀតបៀនរឿយៗ ,

៣. អនត្តា ប្រែថា មិនមានខ្លឹមសារ មិនលុះក្នុងអំណាចនៃជនណា ។

(មានក្នុង សីលកថាសង្ខេប)

( ពិនិត្យដោយ ៖ ព្រះគ្រូធម្មាចារ្យ យូ ប៉ែម យាន៊ិកត្ថេរ. រៀបរៀងដោយ ៖ ព្រះភិក្ខុ យូ ប៊ុនធី បុណ្ណធម្មោ. លោក បាស់ ម៉េងហួត )

## ៨. វិបស្សនូបក្កិលេស :

ធម៌ ជាគ្រឿងសៅហ្មងដល់វិបស្សនា ហៅថា

វិបស្សនូបក្កិលេស មាន ១០ យ៉ាង :

១. ឱភាសោ គឺ ពន្លឺ ,

២. ញាណ គឺ ប្រាជ្ញាក្លៀវក្លា ,

៣. បីតិ គឺ សេចក្តីឆ្អែតកាយ និង ចិត្ត ,

៤. បស្សទ្ធិ គឺ សេចក្តីស្ងប់កាយ និង ចិត្ត ,

៥. សុខំ គឺ សេចក្តីស្រួលកាយ និង ចិត្ត ,

៦. អធិមោក្ខោ គឺ សទ្ធា ជឿស៊ប់ ,

៧. បគ្គាហោ គឺ វិរិយៈសេចក្តីព្យាយាម មិនតឹងពេក មិនធូរពេក ។

៨. ឧបដ្ឋានំ គឺ សតិស្មារតីតាំងនៅមាំល្អ ។

៩. ឧបេក្ខា គឺ ការសោយអារម្មណ៍ស្មើ ៗ ព្រងើយកន្តើយ ចំពោះសង្ខារទាំងពួង ។

១០. និកន្តិ គឺ សេចក្តីប្រាថ្នាដ៏ស្ងប់ល្អិត ចំពោះធម៌

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យាទិកត្ថេរ, រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនធី បុណ្ណធម្មោ, លោក ហាស់ ម៉េងហួត )

មានឱភាសជាដើម ។

ឧបក្កិលេស ទាំង ១០ នេះ ព្រះយោគីគប្បីលះបង់ដោយធ្វើទុកក្នុងចិត្តថា "មិនមែនអញមិនមែនរបស់អញ" ។

(មាននៅក្នុង សីលកថាសង្ខេប)

## ៩. អនុបស្សនា :

បញ្ញាឃើញរឿយៗហៅថាអនុបស្សនា

មាន ៧យ៉ាង គឺ :

១. អនិច្ចានុបស្សនា បញ្ញាឃើញសង្ខារមិនទៀង។

២. ទុក្ខានុបស្សនា បញ្ញាឃើញសង្ខារជាទុក្ខ ។

៣. អនត្តានុបស្សនា បញ្ញាឃើញសង្ខារ គ្មានខ្លឹមសារ មិនលុះក្នុងអំណាចនៃជនណា ។

៤. និព្វិទានុបស្សនា បញ្ញានឿយណាយ ។

៥. វិរាគានុបស្សនា បញ្ញាប្រាសចាកតម្រេក ។

៦. និរោធានុបស្សនា  បញ្ញារំលត់បង់ ។

៧. បដិនិស្សគ្គានុបស្សនា  បញ្ញារលាស់ចោល ។

## សិក្សាអំពី កិលេស និង ធម៌

១. កិលេសគ្រោតគ្រាត ១០ គឺ ទុច្ចរិត ១០យ៉ាង ដូច កុសលកម្មបថ ១០ ដែរ ។

២. នីវរណធម៌ ធម៌ជាគ្រឿងរាំង៥យ៉ាង មាន កាមច្ឆន្ទះ ជាដើម ។  (មានក្នុង សីលកថាសង្ខេប)

៣. កិលេសឆាំងត្រៃលក្ខណ៍

- លោភៈ ធម្មជាតិជាប់ជំពាក់ក្នុងអារម្មណ៍ បាំងអនិច្ចំ ។
- ទោសៈ ធម្មជាតិប្រទុស្ស ក្នុងអារម្មណ៍ បាំងទុក្ខំ ។
- មោហៈ ធម្មជាតិវង្វេងក្នុងអារម្មណ៍បាំងអនត្តា ។

## ធម៌ ៧ ជាធម៌បដិបក្ខ និង ធម៌ ៧ :

១. និច្ចសញ្ញា សេចក្ដីសំគាល់ថា ទៀងជាសត្រូវ ដល់អនិច្ចានុបស្សនា ។

២. សុខសញ្ញា សេចក្តីសំគាល់ថា សុខជាសត្រូវដល់ទុក្ខានុបស្សនា ។

៣. អត្តសញ្ញា សេចក្តីសំគាល់ថា ខ្លួនជាសត្រូវដល់អនត្តានុបស្សនា ។

៤. នន្ទិ សេចក្តីរីករាយ ជាសត្រូវដល់ និព្វិទានុបស្សនា ។

៥. រាគៈ តម្រេកជាសត្រូវដល់ វិរាគានុបស្សនា ។

៦. សមុទយៈ ធម៌ជាហេតុ នាំអោយកើតជាសត្រូវដល់និរោធានុបស្សនា ។

៧. អាទាន សេចក្តីប្រកាន់មាំ ជាសត្រូវដល់បដិនិស្សគ្គានុបស្សនា ។

ធម៌ទាំង ៧នេះជាបដិបក្ខនឹងគ្នា, ធម៌មាន អនិច្ចានុបស្សនាជាដើម ជាប៉ែកខាងកុសល, ធម៌ ៧មានអនិច្ចសញ្ញាជាដើមប៉ែកខាងអកុសល ។

# បរិញ្ញា

បរិញ្ញា គឺ បញ្ញាហ្នឹងឯង មាន ៣ យ៉ាងគឺ :

១. ញាតបរិញ្ញា មានន័យថា បញ្ញា ប្រែថាកំណត់ដឹង គឺ បញ្ញាដែលកំណត់ដឹងនូវ លក្ខណៈ រូបធម៌ នាមធម៌ ព្រមទាំងបច្ច័យ ។

២. តីរណបរិញ្ញា មានន័យថា បញ្ញា ប្រែថាពិចារណាថ្លឹងថ្លែង បែងចែក. . .គឺ បញ្ញាដែលពិចារណាឃើញត្រៃលក្ខណ៍ហ្នឹងឯងមាន ពិចារណាថា រូបំ អនិច្ចំ ជាដើម ។

៣. បហានបរិញ្ញា មានន័យថា បញ្ញា ប្រែថា លះបង់បានដល់ អនុបស្សនា ៧ មានអនិច្ចានុបស្សនា ៧ មានអនិច្ចានុបស្សនា លះបង់និច្ចសញ្ញា ជាដើម ។

# ទសធម្មសុត្តបាឋៈ

១. វេវណ្ណិយម្ហិ អជ្ឈុបគតោ : អាត្មាអញមានភេទផ្សេងអំពីគ្រហស្ថ ។

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ ឃូ ប៉ែម យានិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ ឃូ ប៊ុនធី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

២. បរប្បដិពទ្ធា មេ ជីវិកា : ការចិញ្ចឹម ជីវិតរបស់ អាត្មាអញ ជាប់ដោយសារអ្នកដ៏ទៃ ។

៣. អញ្ញោ មេ អាកប្បោ ករណីយោ : អាត្មាអញត្រូវធ្វើអាកប្បកិរិយា (អំពើដោយ កាយនិងវាចា) ផ្សេងដ៏ទៃប្លែកពីគ្រហស្ថ ។

៤. កច្ចិ នុ ខោ អត្តា សីលតោ ន ឧបវទតិ ?: ចិត្តរបស់អាត្មាអញ មិនតិះដៀលខ្លួនឯង ព្រោះសីល (មិនបរិបូរណ៍) ទេឬ?

៥. កច្ចិ នុ ខោ មំ អនុវិច្ច វិញ្ញូ សព្រហ្មចារី សីលតោ ន ឧបវទន្តិ ? : ពួកសព្រហ្មចារីជាអ្នកប្រាជ្ញពិចារណាហើយ មិនតិះដៀល អាត្មាអញព្រោះ សីល (មិនបរិបូរណ៍) ទេឬ ?

៦. សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ : អាត្មាអញគង់តែ ព្រាត់ប្រាសនិរាស ចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ ពេញចិត្តទាំងអស់ពុំខាន ។

៧. កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ, យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ : អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឱ្យផល មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពុំនាក់អាស្រ័យ. អាត្មាអញនឹងធ្វើកម្មណា ជាកម្មល្អក្តី អាក្រក់ក្តី អាត្មាអញនឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះពុំខាន ។

៨. កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តិ ? យប់និងថ្ងៃកន្លងទៅ អាត្មាអញបានធ្វើអ្វីខ្លះ ?

៩. កច្ចិ នុ ខោហំ សុញ្ញាគារេ អភិរមាមិ ? អាត្មាអញត្រេកអរ ក្នុងផ្ទះស្ងាត់ឬទេ ?

១០. អត្ថិ នុ ខោ មេ ឧត្តរិមនុស្សធម្មោ អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ ? សោហំ បច្ឆិមេ កាលេ សព្រហ្មចារីហិ បុដ្ឋោ ន មង្កុ ភវិស្សាមិ ។ អាត្មាអញមានឧត្តរិ មនុស្សធម៌ដែរឬទេ ?

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យានិកត្ថេរ, រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនធី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

អាត្មាអញបានលុះគុណវិសេស គឺញាណនិងទស្សនៈដ៏ប្រសើរ ជាធម៌ អាចកម្ចាត់បង់ នូវកិលេសដែរឬទេ ?

បើពួកសព្រហ្មចារីមកសួរក្នុងបច្ឆិមកាល អាត្មាអញឯង នឹងមិនអៀនខ្មាស់ឡើយ ។

## សេខិយវត្ត

ពាក្យថា " សេខិយវត្ត " នេះជាវត្ត ឬជាទំនៀមដែលភិក្ខុគប្បីសិក្សា គឺ គប្បីបដិបត្តិតាម បើមិនបានបដិបត្តិតាម ត្រូវអាបត្តិទុក្កដមិនមែនសំដៅដល់ការសិក្សារៀនសូត្រអោយដឹងនោះទេ ។

សេខិយវត្ត ចែកចេញជាពួកមាន ៤ពួក នោះគឺ :

១- សារូប គឺ ទំនៀមដែលភិក្ខុ គប្បីប្រព្រឹត្តក្នុងវេលា ដែលចូលទៅកាន់ភូមិ ១ពួក រួមមាន ២៦សិក្ខាបទ ។

២- ភោជន បដិសំយុត្ត គឺ ទំនៀមដែលភិក្ខុគប្បីប្រព្រឹត្តក្នុងវេលាដែលទទួលបិណ្ឌបាត នឹងវេលាដែលឆាន់ ១ពួក រួមមាន ៣០សិក្ខាបទ ។

៣- ធម្មទេសនា បដិសំយុត្ត គឺ ទំនៀមដែលភិក្ខុមិនគួរសំដែងធម៌ ដល់បុគ្គលដែលមិនគោរព ១ពួក រួមមាន ១៦សិក្ខាបទ ។

៤- បកិណ្ណក គឺ ទំនៀមដែលភិក្ខុគប្បីប្រព្រឹត្ត ក្នុងវេលាដែលបន្ទោបង់នូវ ឧច្ចារៈ និង បស្សាវៈ ១ពួក រួមមាន ៣សិក្ខាបទ ។

## គរុទោស ១៦យ៉ាង

១- គរុហនិន្ទា ត្មះតិះដៀល និយាយដើមគ្រូ ។

២- វិវាទោ ឈ្លោះទាស់ទែងនឹងគ្រូ ។

៣- ឥស្សំ ឬស្សានឹងគ្រូ ។

៤- ធនចោរកោ លួចទ្រព្យគ្រូ ។

៥- ឧច្ចាសយនំ ដេកខ្ពស់ជាងគ្រូ ។

៦- អនិរយោ មិនអើពើនឹងគ្រូ ។

៧- វាចាតិក្កន្តោ និយាយស្កាត់ពាក្យគ្រូ ។

៨- គរុវដ្ឋានុដ្ឋាន គ្រូក្រោកខ្លួនមិនក្រោក ។

៩- អញ្ញវន្ទនំ ទៅសំពះគ្រូដទៃក្រៅសាសនា ។

‹ ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យានិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនធី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត ›

១០- ហីសាចិន្តនំ    គិតបៀតបៀនគ្រូ ។

១១- បសំសនំ    ទៅសរសើគ្រូដទៃក្រៅសាសនា ។

១២- នោបការំ    មិនធ្វើឧបការៈនឹងគ្រូ ។

១៣- អញ្ញសត្ថាគរុបូជា    ទៅគោរពគ្រូក្រៅសាសនា

១៤- គរុទុក្ខំ    ធ្វើអោយគ្រូកើតទុក្ខ ។

១៥- វិនាសនំ    ធ្វើអោយគ្រូវិនាស ។

១៦- គរុក្រុលំ    ប្រុស្តត្រកូលគ្រូ ។

ឧទ្ទិដ្ឋា    ខោ    អាយស្មន្តោ    (    បញ្ចសត្តតិ    )

សេខិយា ធម្មា ។

បពិត្រលោកអ្នកមានអាយុទាំងឡាយ វត្តដែលគប្បីសិក្សាទាំង (ចិតសិបប្រាំ) ខ្ញុំព្រះករុណាបានសំដែងរួចហើយ ។

តត្ថាយស្មន្តេ បុច្ឆាមិ , កច្ចិត្ថ បរិសុទ្ធា ?

ខ្ញុំព្រះករុណា សូមសួរលោកអ្នកមានអាយុទាំងឡាយ ក្នុងសេខិយវត្តទាំងនោះ, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ?

ទុតិយម្បិ បុច្ឆាមិ , កច្ចិត្ថ បរិសុទ្ធា ?

ខ្ញុំព្រះករុណាសូមសួរជាគម្រប់ពីរដងទៀត, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ?

តតិយម្បិ បុច្ឆាមិ , កច្ចិត្ថ បរិសុទ្ធា ?

ខ្ញុំព្រះករុណាសូមសួរជាគម្រប់បីដងទៀត , លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ?

បរិសុទ្ធេត្ថាយស្មន្តោ , តស្មា តុណ្ហី ៗ

លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធ ក្នុងសេខិយវត្តទាំងនុ៎ះហើយ,ព្រោះហេតុនោះបានជានៅស្ងៀម ។

ឯវមេតំ ធារយាមិ ៗ

ខ្ញុំព្រះករុណា សូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

សេខិយា និដ្ឋិតា ៗ

ចប់ សេខិយវត្ត ។

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យានិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

# ភិក្ខុប្បាតិមោក្ខបាលី

ឥមេ ខោ បនាយស្មន្តោ (បញ្ចសត្តតិ(១))
សេខិយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

ប្រែថា: បពិត្រលោកអ្នកមានអាយុទាំងឡាយ ! វត្ថុគប្បីសិក្សាទាំងឡាយ (ចិតសិបប្រាំ) នេះឯង មកកាន់ឧទ្ទេស (គឺការសម្តែងឡើង) ។

១. បរិមណ្ឌលំ និវាសេស្សាមីតិ សិក្ខា ករណីយា ។១។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា (១) ថា "អាត្មាអញ នឹងស្លៀកស្បង់ឱ្យជាបរិមណ្ឌល " ។

២. បរិមណ្ឌលំ បារុបិស្សាមីតិ សិក្ខា ករណីយា ។២។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងដណ្តប់ (គឺគ្រង) ចីពរឱ្យជាបរិមណ្ឌល "។

៣. សុប្បដិច្ឆន្នោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ២៣២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងបិទបាំងកាយ (គឺឃ្លុំ) ឱ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ "។

៤. សុប្បដិច្ឆន្នោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ២៤២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងបិទបាំងកាយ (គឺឃ្លុំ) ឱ្យល្អ អង្គុយក្នុងចន្លោះផ្ទះ "។

៥. សុសំវុតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ២៥២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងសង្រួមឱ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ "។

៦. សុសំវុតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ២៦២

ប្រែថា:  ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញ នឹងសង្រួម ឲ្យល្អ អង្គុយក្នុងចន្លោះផ្ទះ "។

៧. ឱក្ខិត្តចក្ខុ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ២៧២

ប្រែថា:  ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងមាន ភ្នែកសំឡឹងចុះ ដើរទៅក្នុងចន្លោះផ្ទះ "។

៨. ឱក្ខិត្តចក្ខុ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ២៨២

ប្រែថា:  ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងមាន ភ្នែកសំឡឹងចុះ អង្គុយក្នុងចន្លោះផ្ទះ "។

៩. ន ឧក្ខិត្តកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ២៩២

ប្រែថា:  ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹង មិនសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ "។

១០. ន ឧក្ខិត្តកាយ អន្តរឃរេ និសីទិស្សាមីតិ

សិក្ខា ករណីយា ៦១០៦

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនសើយចីវរ អង្គុយក្នុងចន្លោះផ្ទះ "។

## បរិមណ្ឌលវគ្គោ បឋមោ ៦

បរិមណ្ឌលវគ្គទី ១ (ចប់) ។

១១. ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គមិស្សាមីតិ

សិក្ខា ករណីយា ៦១៦

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ "។

១២. ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិស្សាមីតិ

សិក្ខា ករណីយា ៦២៦

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនសើចខ្លាំង អង្គុយក្នុងចន្លោះផ្ទះ "។

១៣. អប្បសទ្ទោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ២៣២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងនិយាយសំលេងតិច ដើរទៅក្នុងចន្លោះផ្ទះ "។

១៤. អប្បសទ្ទោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ២៤២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងនិយាយសំលេងតិច អង្គុយក្នុងចន្លោះផ្ទះ "។

១៥. ន កាយប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ២៥២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងមិនគ្រវែងកាយ ដើរទៅក្នុងចន្លោះផ្ទះ "។

១៦. ន កាយប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ២៦២

ប្រែថា:      ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹង មិនត្រលែងកាយ អង្គុយក្នុងចន្លោះផ្ទះ "។

១៧_ ន   ពាហុប្បចាលកំ   អន្តរឃរេ   គមិស្សាមីតិ សិក្ខា ករណីយា ២៧២

ប្រែថា:      ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹង មិនបង់បោយ ដើរទៅក្នុងចន្លោះផ្ទះ "។

១៨_ ន   ពាហុប្បចាលកំ   អន្តរឃរេ   និសីទិស្សាមីតិ សិក្ខា ករណីយា ២៨២

ប្រែថា:      ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹង មិនផ្ការដៃ អង្គុយក្នុងចន្លោះផ្ទះ "។

១៩_ ន   សីសប្បចាលកំ   អន្តរឃរេ   គមិស្សាមីតិ សិក្ខា ករណីយា ២៩២

ប្រែថា:      ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹង មិនអង្រួនក្បាល ដើរទៅក្នុងចន្លោះផ្ទះ "។

២០_ន សីសប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។១០។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនអង្រួនក្បាល អង្គុយក្នុងចន្លោះផ្ទះ "។

ខុជ្ជគ្ឃិកវគ្គោ ទុតិយោ ។

ឧជ្ជគ្ឃិក វគ្គទី ២ ( ចប់ ) ។

២១_ន ខម្ភកតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។១។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនយកដៃស្ទឹមចង្កេះ ដើរទៅក្នុងចន្លោះផ្ទះ "។

២២_ន ខម្ភកតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។២។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនយកដៃស្ទឹមចង្កេះ អង្គុយក្នុងចន្លោះផ្ទះ "។

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យាទិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

២៣_ន ឱគុណ្ឋិតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ឬ៣ឬ

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះ "។

២៤_ន ឱគុណ្ឋិតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ឬ៤ឬ

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនទទូរក្បាល អង្គុយក្នុងចន្លោះផ្ទះ "។

២៥_ន ឧក្កុដិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ឬ៥ឬ

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនចំអើតជើង ដើរទៅក្នុងចន្លោះផ្ទះ "។

២៦_ន បល្លត្ថិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ឬ៦ឬ

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យានិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនអង្គុយត្របោមក្បាលជង្គង់ ក្នុងចន្លោះផ្ទះ "។

ឆព្វីសតិ សារុប្បា ២

(ចប់) សារុប្បម្ភៃប្រាំមួយ ។

២៧- សក្កច្ចំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខាករណីយា ២៧២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងទទួលអាហារបិណ្ឌបាតដោយគោរព " ។

២៨- បត្តសញ្ញី បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខាករណីយា ២៨២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងសម្គាល់តែក្នុងបាត្រទទួលបិណ្ឌបាត " ។

២៩- សមសូបកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខាករណីយា ២៩២

ប្រែថា:		ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងទទួលបិណ្ឌបាត ឱ្យល្មមគ្នានឹងសម្ល " ។

៣០. សមតិត្តិកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ៚១០៚

ប្រែថា:		ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងទទួលបិណ្ឌបាត ឱ្យស្មើត្រឹមកណ្តាប់មាត់បាត្រ " ។

ខម្ពកវគ្គោ តតិយោ ៚

ខម្ពកវគ្គទី ៣ ( ចប់ ) ។

៣១. សក្កច្ចំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៚១៚

ប្រែថា:		ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងឆាន់បិណ្ឌបាតដោយគោរព " ។

៣២. បត្តសញ្ញី បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៚២៚

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យានិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងសម្គាល់តែក្នុងបាត្រឆាន់បិណ្ឌបាត " ។

៣៣‑ សបទានំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៗ៣ៗ

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងឆាន់បិណ្ឌបាត រៀចឱ្យស្មើ " ។

៣៤‑ សមសូបកំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៗ៤ៗ

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងឆាន់បិណ្ឌបាតឱ្យល្មមគ្នានឹងសម្ល " ។

៣៥‑ ន ថូបតោ ឱមទ្ទិត្វា បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៗ៥ៗ

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងមិនច្របាច់ត្រង់កំពូលបាយហើយឆាន់បិណ្ឌបាត " ។

៣៦~ ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេស្សាមិ ភិយ្យោកម្យតំ ឧបាទាយាតិ សិក្ខា ករណីយា ៕៣៦៕

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនកកាយបាយលុប សម្ល ឬ ម្ហូប ព្រោះអាស្រ័យសេចក្តីលោភច្រើន " ។

៣៧~ ន សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៕៣៧៕

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ ឥតមានជំងឺ នឹងមិនសូមសម្ល ឬបាយ ដើម្បីប្រយោជន៍ខ្លួនឯងហើយឆាន់ " ។

៣៨~ ន ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេស្សាមីតិ សិក្ខា ករណីយា ៕៣៨៕

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនប្រុងលើកទោសហើយ សម្លឹងមើលបាត្រពួកភិក្ខុដទៃ " ។

៣៩~ នាតិមហន្តំ កពឡំ ករិស្សាមីតិ សិក្ខា ករណីយា ២៩២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនធ្វើពំនូតបាយ ឱ្យធំពេក " ។

៤០~ បរិមណ្ឌលំ អាលោបំ ករិស្សាមីតិ សិក្ខា ករណីយា ២១០២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងធ្វើពំនូតបាយ ឱ្យជាបរិមណ្ឌលគឺឱ្យមូល " ។

សក្កច្ចវគ្គោ ចតុត្ថោ ២

សក្កច្ចវគ្គទី ៤ ( ចប់ ) ។

៤១~ ន អនាហដេ កពឡេ(១) មុខទ្វារំ វិវរិស្សាមីតិ សិក្ខា ករណីយា ២១២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញកាលពំនូតបាយមិនទាន់មកដល់ នឹងមិនបើកទ្វារមាត់ចាំ " ។

៤២. ន កពឡមានោ សព្វំ ហត្ថំ មុខេ បក្ខិបិស្សាមីតិ សិក្ខា ករណីយា ៕២៕

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញ កាលឆាន់នឹងមិនញាត់ម្រាមដៃទាំងអស់ ចូលទៅក្នុងមាត់ " ។

៤៣. ន សកពឡេន មុខេន ព្យាហរិស្សាមីតិ សិក្ខា ករណីយា ៕៣៕

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញ នឹងមិននិយាយទាំងពំនូតបាយនៅក្នុងមាត់ " ។

៤៤. ន បិណ្ឌុក្ខេបកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៕៤៕

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញ នឹងមិនឆាន់បោះដុំបាយទៅក្នុងមាត់ " ។

៤៥. ន កពឡាវច្ឆេទកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៕៥៕

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនឆាន់កាត់ពំនូតបាយ " ។

៤៦_ ន អវគណ្ឌការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ២៦២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនឆាន់បៀមពំនូតបាយក្នុងថ្ពាល់ " ។

៤៧_ ន ហត្ថនិទ្ធូនកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ២៧២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនឆាន់រលាស់ដៃ " ។

៤៨_ ន សិត្ថាវការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ២៨២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនឆាន់ធ្វើគ្រាប់បាយឱ្យជ្រុះរោយរាយ " ។

៤៩. ន ជិវ្ហានិច្ឆារកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៕៩៕

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនឆាន់លៀនអណ្តាត " ។

៥០. ន ចបុចបុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៕១០៕

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនឆាន់ធ្វើសូរឱ្យឮផ្លប់ៗ " ។

## កពឡវគ្គោ បញ្ចមោ ៕

កពឡ វគ្គទី ៥ (ចប់) ។

៥១. ន សុរុសុរុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ៕១៕

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនឆាន់ធ្វើសូរឱ្យឮគ្រូកៗ " ។

៥២_ ន ហត្ថនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ១២១

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនឆាន់លិទ្ធដៃ " ។

៥៣_ ន បត្តនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ១៣១

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនឆាន់លិទ្ធបាត្រ " ។

៥៤_ ន ឱដ្ឋនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ១៤១

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនឆាន់លិទ្ធបបូរមាត់ " ។

៥៥_ ន សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ១៥១

ប្រែថាៈ ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា"អាត្មាអញមានដៃប្រឡាក់ដោយអាមិស នឹងមិនទទួលភាជនៈទឹកសម្រាប់ឆាន់ " ។

៥៦_ ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេស្សាមីតិ សិក្ខា ករណីយា ៤៦៤

ប្រែថាៈ ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងមិនចាក់ទឹកលាងបាត្រទាំងគ្រាប់បាយ ក្នុងចន្លោះផ្ទះ " ។

សមត្តឹស ភោជនប្បដិសំយុត្តា ៤

(ចប់) ភោជនប្បដិសំយុត្ត ៣០ គត់ ។

៥៧_ ន ឆត្តបាណិស្ស អគ្គិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ៤៧៤

ប្រែថាៈ ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ មានឆត្រក្នុងដៃ " ។

៥៨_ ន ទណ្ឌបាណិស្ស អគ្គិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ៤៨៤

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនសំដែងធម៌ដល់មនុស្សគ្មានជំងឺ មានដំបងក្នុងដៃ " ។

៥៩. ន សត្ថបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។៥៩។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនសំដែងធម៌ដល់មនុស្សគ្មានជំងឺ មានគ្រឿងសស្ត្រាក្នុងដៃ " ។

៦០. ន អាវុធបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។៦០។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនសំដែងធម៌ដល់មនុស្សគ្មានជំងឺ មានគ្រឿងអាវុធក្នុងដៃ " ។

សុរុសុរុវគ្គោ ឆដ្ឋោ ។

សុរុសុរុវគ្គទី ៦ (ចប់) ។

៦១. ន បាទុការុឡ្ហស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។៦១។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ពាក់ទ្រនាប់ជើង " ។

៦២. ន ឧបាហនារុឡ្ហស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។២២។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ពាក់ស្បែកជើង " ។

៦៣. ន យានគតស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។២៣។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ នៅលើយាន " ។

៦៤. ន សយនគតស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។២៤។

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា ថា " អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ នៅលើដំណេក " ។

៦៥. ន បល្លត្ថិកាយ និសន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ២៥២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយត្របោមក្បាលជង្គង់ "។

៦៦. ន វេដ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ២៦២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ជួតក្បាល " ។

៦៧. ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ២៧២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ទទូរក្បាល " ។

៦៨. ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ២៨២

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនអង្គុយផ្ទាល់នឹងផែនដី ហើយសម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈ " ។

៦៩. ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ៥៩៥

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញនឹងមិនអង្គុយលើអាសនៈទាប ហើយសម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈខ្ពស់ " ។

៧០. ន ឋិតោ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ៥១០៥

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនឈរសម្តែងធម៌ដល់មនុស្ស គ្មានជំងឺ ដែលអង្គុយ " ។

៧១- ន បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ៚១១១៚

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនដើរខាងក្រោយសម្តែងធម៌ដល់មនុស្ស គ្មានជំងឺ ដើរខាងមុខ "។

៧២- ន ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ៚១២២៚

ប្រែថា: ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញ នឹងមិនដើរក្រៅផ្លូវ សម្តែងធម៌ដល់មនុស្សគ្មានជំងឺ ដើរតាមផ្លូវ " ។

សោឡស ធម្មទេសនាបដិសំយុត្តា ៚

(ចប់) ទេសនាបដិសំយុត្ត ១៦ ។

៧៣- ន ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករិស្សាមីតិ សិក្ខា ករណីយា ៚១៣៚

ប្រែថា៖ ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញគ្មានជំងឺ នឹងមិនឈរបន្ទោបង់ ឧច្ចារៈ ឬ បស្សាវៈ " ។

៧៤. ន ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។១៤។

ប្រែថា៖ ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញគ្មានជំងឺ នឹងមិនបន្ទោបង់ ឧច្ចារៈ ឬ បស្សាវៈ ឬក៏ស្តោះទឹកមាត់លើស្មៅស្រស់ ឬឈើស្រស់ " ។

៧៥. ន ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។១៥។

ប្រែថា៖ ភិក្ខុគប្បីធ្វើសេចក្តីសិក្សា ថា " អាត្មាអញគ្មានជំងឺ នឹងមិនបន្ទោបង់ ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្តោះទឹកមាត់លើទឹក" ។

**តយោ បកិណ្ណកា និដ្ឋិតា ។**

(ចប់) បកិណ្ណកៈ ៣ ។

**បាទុកាវគ្គោ សត្តមោ ។**

បាទុកា វគ្គទី ៧ (ចប់) ។

# ក. បុគ្គលមានទ្រព្យធ្វើបុណ្យមិនកើត ដោយធម៌ ២ យ៉ាងគឺ

១. បមាទៈ សេចក្តីប្រមាទ

២. មច្ឆរិយៈ សេចក្តីកំណាញ់

## ខ. ចំណង ១០ ប្រការ :

១. មាតា លោកេ ពន្ធនំ ចំណង មាតា

២. បិតា លោកេ ពន្ធនំ ចំណង បិតា

៣. ភរិយា លោកេ ពន្ធនំ ចំណង ភរិយា

៤. ញាតិ លោកេ ពន្ធនំ ចំណង ញាតិ

៥. មិត្ត លោកេ ពន្ធនំ ចំណង មិត្ត

៦. ធន លោកេ ពន្ធនំ ចំណង ទ្រព្យ

៧. លាភៈ សក្ការៈ លោកេ ពន្ធនំ ចំណង លាភ

៨. ឥស្សរិយ លោកេ ពន្ធនំ ចំណង យសស័ក្ក

៩. បញ្ចកាមគុណាលោកេ ពន្ធនំ ចំណង ក្នុងកាម

១០. បុត្ត លោកេ ពន្ធនំ ចំណង កូន។

## គ. ទោសនៃចំរៀងមាន ៥យ៉ាង គឺ :

១. អត្តនោ បិ តស្មី សរេសារជ្ជតិ អ្នកចំរៀង តែងត្រេកអរ និង សំលេងរបស់ខ្លួន ។

២. បរេបិ តស្មី សរេ សារជ្ជតិ អ្នកដ៏ទៃរមែងត្រេកអរ។

៣. គហបតី ឧជ្ឈាយន្តិ គហបតី រមែងតិះដៀល។

៤. សរកុត្តីបិ និកមយមានស្ស សាមាធិស្ស សង្គោ ហោតិ អ្នកសូត្របុអ្នកច្រៀងរមែង ខូចសម្មាធិ។

៥. មច្ឆិមា ជនតា ទិដ្ឋានុគតិ ជនខាងក្រោយ រមែងយកតំរាប់តាម ។

## ឃ. ទានដែលជាអសប្បុរសទាន មាន ៥យ៉ាងគឺ :

១. ឥត្ថី ទានំ អោយស្រី ដល់ បុរស រឺអោយបុរស ដល់ ស្ត្រី។

‹ ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យាទិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត ›

២. ខ្វសត ឆានំ បើកលែងគោបា អោយដល់ គោញី រឺ

បើកលែង គោញី អោយគោបា ។

៣. មជ្ជ ឆានំ អោយទឹកស្រវឹង ។

៤. សមជ្ជ ឆានំ រាំ និង ច្រៀង អោយជាទាន ។

៥. ចិត្តកម្មឆានំ អោយទានរូបគំនូរស្រ្តី និង បុរសដែលជារូប

អោយកើតត្រេកត្រអាល ទៅរកកាម ។

## ខ. គុណមាន ៤យ៉ាង គឺ:

១. អនន្តគុណ គុណដែលរាប់មិនបាន ។

២. អនេកប្បគុណ គុណច្រើនអនេក ។

៣. អសមគុណ គុណឥតអ្វីប្រៀបស្មើ ។

៤. អបរិមាណគុណ គុណប្រមាណមិនបាន ។

គុណលោកប្រៀបឧបមាថា អោយយកផែនដីធ្វើជាសៀវភៅ យកភ្នំព្រះសុមេរុធ្វើជាដងប៉ាកកា យកទឹកនព្វមហាសមុទ្រ ធ្វើជាទឹកខ្មៅ ហើយសរសេររៀបរាប់ តែអំពីគុណរបស់ មាតា បិតា អោយត្រាតែអស់ ផែនដី នឹងរេចរិល

ភ្នំសុមេរុ ព្រមទាំង នឹងទឹកនព្វមហាសមុទ្រក៏នៅតែមិនអស់គុណ មាតា បិតាផង បានជាព្រះពុទ្ធ ត្រាស់សំដែងថា : តេហិ អន្តរេន មាតាបិតូនំ នប្បមជ្ជិតព្វំ អ្នកទាំងឡាយមិនគប្បីប្រមាថ មើលងាយចំពោះ មាតា បិតា របស់ខ្លួនទេ ព្រោះ មាតាបិតា ជាអ្នកមានគុណដ៏ធ្ងន់ យើងត្រូវតែគោរពប្រតិបត្តិស្រឡាញ់ រាប់អាន កោតខ្លាចទាំងយប់ទាំងថ្ងៃ ។

## ច. សមណៈ ប្រកបដោយអង្គ ៤ គឺ :

១ ខន្តី : ចេះអត់ធន់ ។

២ អប្បមាទោ : មិនប្រមាថក្នុងកុសលធម៌ ។

៣ វត្ថិបហានំ : លះបង់សេចក្ដីត្រេកអរក្នុងកាម ។

៤ អកិញ្ចនំ : មិនមានកង្វល់ ។

## ឆ. ធម៌ធ្វើអោយកើតសីល ២យ៉ាង :

១- ហិរិ : ធម្មជាតិដែលអៀនខ្មាស់ និងអំពើទុច្ចរិត ។

២- ឱត្តប្ប : ធម្មជាតិដែលតក់ស្លុត និងផលរបស់អំពើទុច្ចរិត ។

ធម៌ទាំងពីរប្រការនេះបើសីល មិនទាន់កើតឡើង ក៏អាចធ្វើឱ្យកើតសីលឡើងបាន ដែលកើតឡើងហើយ ក៏អាចឱ្យតាំងនៅដោយបរិសុទ្ធិបាន ។

ហិរិ និង ឱត្តប្ប : ពីរនេះខ្លះហៅថា ខ្សែសំរាប់ ទប់សីល ឬសំរាប់ ចងសីលអោយនៅនឹងនបាន ។

គម្ពីរវិសុទ្ធមគ្គ ភាគ ១ ទំព័រ ១៥ ត្រង់សីលនិទ្ទេស

# សមថវិបស្សនាកម្មដ្ឋាន

## ការសិក្សាសមថ និង វិបស្សនាកម្មដ្ឋាន

## ដោយបទសង្ខេប

ជាបឋមលោកអ្នកដែលជាយោគីអ្នកប្រតិបត្តិថ្មី គប្បីយល់ពាក្យថា " សមថ វិបស្សនា កម្មដ្ឋាន " ការធ្វើចិត្តអោយស្ងប់

ចាកអារម្មណ៍ ការហ្វឹកចិត្តអប់រំចិត្តឱ្យតាំង នូវលើអារម្មណ៍តែមួយ ហៅថា សមថកម្មដ្ឋាន។ ចិត្តដែលឈរនៅអារម្មណ៍ដែលមានសតិ ( គឺស្មារតី ) រលឹកដឹងតាមមើលការប្រែប្រួល ខណៈចិត្តដែលវិវឌ្ឍន៍ ទៅតាម អារម្មណ៍ផ្សេងៗ មានរូប សម្លេង ក្លិន រស និងការ ប៉ះពាល់ជាដើម មានសតិបញ្ញាឃើញច្បាស់ នូវសភាវនោះៗ ហៅថា វិបស្សនាកម្មដ្ឋាន ។

## ជាដំបូងលោកអ្នកប្រតិបត្តិត្រូវ :

១- ជំរះ មុជទឹកជំរះកាយឱ្យស្អាត

២- សមាទាន សីល៥ ឬ សីល៨

៣- នមស្សការព្រះរតនត្រៃ និងសូត្រមន្តផ្សេងៗ

៤- សុំព្រះកម្មដ្ឋាន ពីព្រះអាចារ្យអ្នកបង្រៀន

# ពាក្យសមាទានព្រះកម្មដ្ឋាន

ឱកាស / ក្នុងឱកាសនេះ ខ្ញុំព្រះករុណាសូមសមាទាន នូវព្រះកម្មដ្ឋាន សូមខណិកៈសមាធិ ឧបចារសមាធិ អប្បនាសមាធិ នឹងវិបស្សនាញាណ ចូរបង្កើតមានក្នុងខន្ធសន្តាន របស់ខ្ញុំព្រះករុណា ខ្ញុំព្រះករុណា នឹងតាំងសតិ កំណត់ទុកនូវខ្យល់ដង្ហើមចេញចូល ខ្យល់ដង្ហើមចូលក៏ដឹង ខ្យល់ដង្ហើមចេញ ក៏ដឹង ៣ដង ឬ ៧ដង ១០០ដង ឬ ១០០០ដង ដោយសេចក្ដីមិនប្រមាទ តាំងតែពេលឥឡូវនេះទៅ ។

# វិធីបដិបត្តិ

អង្គុយសមាធិ ជើងស្ដាំដាក់លើជើងឆ្វេង ដៃស្ដាំដាក់លើដៃឆ្វេង តាំងកាយឱ្យត្រង់ ងើបមុខឱ្យត្រង់កុំឱនមុខចុះ ហើយបិទភ្នែកចុះ ធ្វើចិត្តឱ្យសប្បាយ កុំធ្វើចិត្តឱ្យទៅចាប់ជាប់នឹង

អ្វីឱ្យសោះ ដកដង្ហើមឱ្យល្មមស្រួល កុំដកខ្លាំងហួសប្រមាណ ឬ កុំដកដង្ហើមឱ្យ ស្រាលហួសប្រមាណ គឺដកដង្ហើមឱ្យល្មម តាមធម្មតា ហើយតាំងសតិកំណត់ដឹង ឱ្យទាន់នូវខ្យល់ដង្ហើម ចេញចូល ខ្ទប់ប៉ះនឹងចុងច្រមុះ ដកដង្ហើមចូលវែង ដកដង្ហើម ចេញវែង ក៏ឱ្យដឹងច្បាស់ ទៅតាមចង្វាក់ដង្ហើមចូល ចេញ ដកដង្ហើមចូល ចេញ ខ្លីក៏ឱ្យដឹងច្បាស់ ។

កុំអោយចិត្តគិតទៅកាន់ទីដទៃ កំណត់វេលា ១-២-៣-៤-៥-៣០ នាទីក្តី ឬ ១ ម៉ោង ២-៣ ម៉ោងក្តី ហើយដម្កល់ អោយនៅនឹងថ្កល់ជាមួយនឹងខ្យល់ដង្ហើមចូល ចេញ អោយតាំង នៅស្ងៀមហ្មត់ទាល់តែដល់ពេលកំណត់ទុក រួចហើយផ្សាយមេត្តា ដល់សព្វសត្វ ផ្សាយ មេត្តា និង អធិដ្ឋាន ។

សព្វេសត្តា សត្វទាំងឡាយទាំងពួង ដែលជាអ្នកមាន សេចក្តីទុក្ខ កើត ចាស់ ឈឺ ស្លាប់ ដូចគ្នាទាំងអស់ ។

អវេរាហោន្តុ ចូរជាសត្វមានសេចក្តីសុខចុះ ។

១- រកអាហារជាទីសប្បាយ តម្រូវនឹងចរិតខ្លួនអ្នកប្រតិបត្តិវិបស្សនា ។

២- ស្វែងរកអាចារ្យជាកល្យាណមិត្រ ដែលជាទីសប្បាយក្នុងការប្រតិបត្តិវិបស្សនា ។

៣- សិក្សាវិបស្សនាភូមិឱ្យយល់សេចក្តី នឹងចូលចិត្តក្នុងការប្រតិបត្តិ ។

៤- នមស្សការព្រះរតនត្រ័យ នឹងសូត្រមន្ត ។

៥- សមាទានសីល ៥-៨ នឹងសមាទានវិបស្សនា ។

## ពាក្យថ្វាយអត្តភាព (ខ្លួន) ដល់ព្រះដ៏មានព្រះភាគ

**ឥមាហំ ភន្តេ ភគវា អត្តភាវំ តុម្ហាកំ បរិច្ចជាមិ**

បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ខ្ញុំព្រះអង្គសូមបង្អោនកាយថ្វាយអត្តភាព នេះ ដល់អង្គសម្តេចព្រះដ៏មានព្រះភាគ ។

## ពាក្យថ្វាយខ្លួនដល់អាចារ្យអ្នកបង្រៀន

**ឥមាហំ ភន្តេ អាចរិយោ អត្តភាវំ**

តុម្ហាកំ បរិច្ចជាមិ

បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាសូមប្រគល់កាយថ្វាយអត្តភាពនេះដល់លោកម្ចាស់ ។

## ពាក្យសុំព្រះវិបស្សនាកម្មដ្ឋាន

និព្វានស្ស មេ ភន្តេ សច្ចិករណត្ថាយ កម្មដ្ឋានំ ទេហិ បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់មេត្តាអោយនូវ ព្រះកម្មដ្ឋានដែល ធ្វើអោយជាក់ច្បាស់នូវព្រះនិព្វានដល់ខ្ញុំព្រះករុណា ។

## ពាក្យសមាទានព្រះវិបស្សនាកម្មដ្ឋាន

ឱកាស / ក្នុងឱកាសនេះ ខ្ញុំព្រះករុណាសូមសមាទាននូវព្រះកម្មដ្ឋាន សូមខណិកៈសមាធិ ឧប្បចារៈសមាធិ អប្បនាសមាធិ និងវិបស្សនាញាណ ចូរបង្កើតមានក្នុងខន្ធសន្តានរបស់ខ្ញុំព្រះករុណា ខ្ញុំព្រះករុណានឹងតាំងសតិ កំណត់ទុកនឹងភ្នែក

ខណៈឃើញ កំណត់ថាពណ៌ជារូប (ឃើញ) សេចក្ដីដឹងថាពណ៌ជានាម ខណៈឮសំលេង តាំងសតិកំណត់ទុកនឹងត្រចៀក កំណត់ថា សំលេងជារូប ( បានឮ )សេចក្ដីជានាម ខណៈធុំក្លិន តាំងសតិទុកនឹងច្រមុះ កំណត់ថាក្លិនជារូប សេចក្ដីដឹងជានាម ខណៈឱជារសមកប៉ះតាំងសតិទុកនឹង អណ្ដាត កំណត់ដឹងថារសជាតិជារូប សេចក្ដីដឹងជានាម ខណៈមានសម្ផស្សប៉ះដោយត្រជាក់ ក្ដៅ ទន់ រឹង តាំងសតិទុកនឹងកាយ កំណត់ថាត្រជាក់ជារូប សេចក្ដីដឹងជានាម ក្ដៅជារូប សេចក្ដីដឹងថាក្ដៅជានាម ទន់ជារូប សេចក្ដីដឹង ជានាម រឹងជារូប សេចក្ដីដឹងជានាម ។ ខណៈនឹកគិតតាមផ្លូវចិត្ត តាំងសតិទុកក្នុងចិត្តកំណត់ថាបេះដូងជារូប សេចក្ដីដឹងការគិតនឹកជានាម ខណៈឈរ តាំងសតិទុកនឹងរូបឈរ កំណត់ថាឈរជារូប សេចក្ដីដឹងថារូបឈរជានាម ខណៈឈានជំហានដើរតាំងសតិកំណត់ទុកនឹងអាការឈានទៅ កំណត់ថាឈានជារូប សេចក្ដីដឹងអាការឈានជានាម ខណៈអង្គុយ តាំងសតិកំណត់ទុក

នឹងរូបអង្គុយ កំណត់ថាអង្គុយជារូប សេចក្តីដឹងថារូបអង្គុយជានាម ខណៈដេក តាំងសតិកំណត់ទុកនឹងរូបដេក កំណត់ថារូបដេកជារូប សេចក្តីដឹង នូវរូបដេកជានាម ខណៈដែលបោះដៃបោះជើង គ្រវាសចុះឡើង កំណត់សតិ តាមការកំរើកបោះឆ្វេងជារូប ដឹងជានាម បោះស្តាំជារូម ដឹងជានាម គ្រវាសចុះឡើងជារូប សេចក្តីដឹងនូវវាសចុះឡើងជានាម ។

នឹងកំណត់ ព្យាយាមកំណត់រូបនាម ដែលជាបច្ចុប្បន្នអោយទាន់គ្រប់ ខណៈដែលចិត្តភ្លើទៅកាន់ទីដទៃ សូម្បីតែលាងមាត់ ដុសធ្មេញ ងូតទឹក ស្លៀកពាក់ ទំពារស៊ីអាហារលេបអាហារ វេលាចូលដេក វេលាក្រោកពីដេក វេលាចូលបង្គន់អោយមានសតិព្រម អោយទាន់គ្រប់ខណៈដែលកំពុងតាំងនៅជាបច្ចុប្បន្ន ។

## កង្វល់ធាំទឡ្ហាយដែលគប្បីលះ

១- វៀរចាក កម្មារាមតា គឺ មិនត្រូវធ្វើកិច្ចការតូចតាចដែល

មិនចាំបាច់ដូចជា អានសៀវភៅ សរសេរជាដើម ។

២- វៀរចាក និទ្ទារាមតា គឺមិនក្លែងដេកលក់ពេលថ្ងៃ ពេលយប់ ដេកតិច ព្យាយាមធ្វើអោយច្រើន ។

៣- វៀរចាក ភស្សារាមតា គឺមិននិយាយគ្នា នឹងអ្នកប្រតិបត្តិជាមួយគ្នា ។

៤- វៀរចាក សង្គណិការាមតា គឺមិនច្របូកច្របល់ក្នុងសង្គម មិនទទួលភ្ញៀវ មិននិយាយនឹងមនុស្សខាងក្រៅ បើចាំបាច់ និយាយជាមួយមនុស្សខាងក្រៅ ត្រូវតែនិយាយអោយតិច ហើយសង្រួមតឹបិទភ្នែកមានសតិរលឹក អោយទាន់គ្រប់ពាក្យ និយាយ ។

៥- វៀរចាក អគុត្តទ្វារតា គឺការមិនសង្រួម ការធ្វេសប្រហែស គឺត្រូវសង្រួមក្នុងទ្វារទាំងពួង មានកាយទ្វារ វិចីទ្វារ មនោទ្វារ ត្រូវប្រតិបត្តិឱ្យខ្ជាប់ខ្ជួនគ្រប់ពេលវៀរលែងតែការដេកលក់ ។

៦-   វៀរចាក ភោជនេ អមត្តញ្ញុតា គឺការបរិភោគហួសប្រមាណ គឺស្គាល់ប្រមាណក្នុងការបរិភោគអាហារឱ្យល្មមសមគួរ នឹងវៀរចាកការញៀនរបស់ដែលឱ្យទោសគ្រប់យ៉ាង មានបារី ស្លា និងគ្រឿងញៀនដទៃទៀត ។

៧-   វៀរចាក វិមុត្តំ ចិត្តំ នបច្ចវេក្ខតិ គឺមិនពិចារណាចិត្តដែលមិនទាន់កើតឡើង និងការកន្លងហួសទៅហើយ ត្រូវពិចារណា កំណត់នូវចិត្តដែលជាបច្ចុប្បន្ន គ្រប់ខណៈចិត្តមិនឱ្យដាច់វយៈ ។

ចូរព្យាយាមតាំងសតិកំណត់រលឹកដឹងនូវរូបនាម ឬសភាវៈធម៌ទាំងឡាយ ឱ្យទាន់ជាប់បច្ចុប្បន្នធម៌ នៅគ្រប់ខណៈដែលកើតឡើង មិនឱ្យភ្លើងសតិវង្វេងស្មារតី ដោយសេចក្តីប្រមាទ ដើម្បីឱ្យ បាននូវ *សីលវិសុទ្ធិ* សីលស្អាតបរិសុទ្ធ *ចិត្តវិសុទ្ធិ* ចិត្តស្អាតបរិសុទ្ធ *ទិដ្ឋិវិសុទ្ធិ* កាលយល់ឃើញស្អាតបរិសុទ្ធ *កង្ខាវិតរណវិសុទ្ធិ* សេចក្តី បរិសុទ្ធ ស្អាតដោយមិនមានសេចក្តីសង្ស័យ ។

មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ សេចក្ដីដឹងឃើញច្បាស់ដ៏បរិសុទ្ធស្អាតថានេះជាផ្លូវទៅកាន់ព្រះនិព្វាន ដោយវិបស្សនាញាណ ( បញ្ញា ) ។

បដិបទាញាណទស្សនវិសុទ្ធិ សេចក្ដីស្អាតបរិសុទ្ធនៃការដឹងឃើញច្បាស់នូវផ្លូវប្រតិបត្តិ គឺ សេចក្ដីព្យាយាមបដិបត្តិក្នុងវិបស្សនា ញាណទាំង ៩ តាំងពីញាណទីមួយរហូតដល់ទី៩ ។

ញាណទស្សនវិសុទ្ធិ ការឃើញច្បាស់នូវព្រះអរិយមគ្គទាំង៤ដ៏បរិសុទ្ធស្អាត ( វិសុទ្ធទាំង ៧ នេះលោកអ្នកប្រតិបត្តិ ត្រូវធ្វើឱ្យជាក់ច្បាស់ដោយបញ្ញាញាណ ដែលកើតឡើង ដោយសេចក្ដីព្យាយាម ហ្វឹកសតិស្មារតីឱ្យជំនាញ ក្នុងការកំណត់ដឹងនូវអារម្មណ៍ដែល មកប៉ះក្នុងទ្វារទាំង៦ ) ។ ដើម្បីតាំងសេចក្ដីព្យាយាម សតិកំណត់ឱ្យដឹងច្បាស់នូវ រូបនាម ដែលកើតរលត់ជាបច្ចុប្បន្ន ជាសន្តិរូប តាំងតែពេលនេះតទៅ ។

# អ្នកប្រតិបត្តិអធិដ្ឋាន

ត្រូវចំរើនទៅតាមមជ្ឈិមបដិបទា គឺមគ្គទាំង ៨ ប្រការ ដែលមានដូចតទៅនេះ :

១. សម្មាទិដ្ឋិ សេចក្តីយល់ឃើញត្រូវ ,

២. សម្មាសង្កប្ប សេចក្តីត្រិះរិះត្រូវ ,

៣. សម្មាវាចា និយាយត្រូវ ,

៤. សម្មាកម្មន្ត ធ្វើការងារត្រូវ ,

៥. សម្មាអាជីវ ចិញ្ចឹមជីវិតត្រូវ ,

៦. សម្មាវាយាម ព្យាយាមត្រូវ ,

៧. សម្មាសតិ រលឹកត្រូវ ,

៨. សម្មាសមាធិ ការតាំងចិត្តត្រូវ, គឺតាំងចិត្តឱ្យនឹងថ្កល់ នៅក្នុងអារម្មណ៍តែមួយ ។

ត្រូវចំរើនតាមមគ្គទាំង ៨ ប្រការ មិនឱ្យតឹងពេក មិនឱ្យធូរថយហួសពេក ឱ្យដឹងនូវបច្ចុប្បន្នធម៌ មិនឱ្យហួសទៅចាប់ យកបញ្ញត្តិ ដែលជាហេតុនាំឱ្យមានសេចក្តីលោភ

សេចក្តីក្រោធ នឹងសេចក្តីវង្វេងកើតឡើងបាន ហើយឱ្យមានសតិ សម្មាធិ បញ្ញា កើតមានឡើងតាមសមគួរ ដល់ព្រះយោគាវចរ អ្នកប្រតិបត្តិ ។

បុព្វហេតុ កាលបើអស់លោកអ្នកប្រតិបត្តិ បានទទួលយក ព្រះកម្មដ្ឋាន ពីសំណាក់លោកគ្រូអាចារ្យហើយ ត្រឡប់ទៅកាន់ បន្ទប់បដិបត្តិកម្មដ្ឋានឬទីកន្លែងស្ងប់ស្ងាត់របស់ខ្លួន ហើយរៀប គ្រឿងសក្ការៈបូជាព្រះរតនត្រ័យមាន ផ្កា ធូប ទាន ដែលជា អាមិសបូជាចុងក្រោយបង្អស់នេះ ព្រោះក្នុងរយៈពេលដែលយើង កំពុងប្រតិបត្តិនោះ មិនឱ្យកង្វល់តទៅទៀត មានតែការ ស្ងឹងស្ងាត់ ប្រតិបត្តិតែម្យ៉ាងបុណ្ណោះ គឺត្រូវតាំងចិត្តឱ្យរឹងមាំ បង្អោនចិត្តចូល ដល់នូវគុណព្រះពុទ្ធរតនៈ គុណព្រះធម៌រតនៈ គុណព្រះសង្ឃរតនៈ រហូតដល់គុណមាតាបិតា គ្រូឧបជ្ឈា យាចារ្យ និងអ្នកដែលមានឧបការៈគុណទាំងឡាយ រហូត ដល់គុណទេវតាទាំងឡាយដែលជា សម្មាទិដ្ឋិ ថែរក្សានូវ ព្រះពុទ្ធសាសនា ដែលស្ថិតនៅ ទីឆ្ងាយក្តី ជិតក្តី គ្រប់ទិសទី

ទាំងពួង ហើយតាំងសច្ចាអធិដ្ឋាន យ៉ាងរឹងមាំថា ក្នុងការប្រតិបត្តិម្តងនេះ បើមិនបានមិនដល់ក្នុង របស់សមគួរបាន គួរដល់នូវសេចក្តីព្យាយាមដោយការអត់ធន់មិនរាថយ ត្រូវប្តេជ្ញាចិត្តដូច្នេះថា សូម្បីតែសាច់ឈាម នៃអវៈយវៈនេះ មានអាការៈរីងស្ងួតអស់ទៅ នៅសល់តែឆ្អឹង សរសៃ ស្បែកក៏ដោយ ក៏យើងមិន លះបង់នូវសេចក្តី ព្យាយាមនេះដើម្បីនឹងធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន តាមសេចក្តីពិត ដែលជាទីបំផុតនៃសេចក្តីទុក្ខ ក្នុងពេលប្រតិបត្តិនេះ ។

( នេះជាសេចក្តីអធិដ្ឋានតាំងចិត្តនៅពេលប្រតិបត្តិម្តងៗ )

ក្រោយពីតាំងសច្ចៈអធិដ្ឋានរួចហើយ គួរកំណត់នូវពេលវេលាឱ្យបានសមគួរ ១៥នាទី ២០នាទី ៣០នាទីក្តី ឬក៏ ១-២-៣-ម៉ោងក្តី តាមតែយើងពេញចិត្ត នៅពេលដែលយើងចំរើន ភាវនា យើងគប្បីផ្សាយមេត្តាដូចតទៅ :

# ផ្សាយមេត្តាចំពោះខ្លួនយើង

អហំ សុខិតោ ហោមិ សូមឱ្យខ្ញុំព្រះករុណា ចូរជាអ្នក
មានសេចក្ដីសុខ ។

អហំ និទ្ទុក្ខោ ហោមិ សូមឱ្យខ្ញុំព្រះករុណា ប្រាសចាកទុក្ខ ។

អហំ អវេរោ ហោមិ សូមឱ្យខ្ញុំព្រះករុណា ប្រាសចាកពៀរ
វេរាទាំងឡាយ ។

អហំ អព្យាបជ្ឈោ ហោមិ សូមឱ្យខ្ញុំព្រះករុណា ប្រាចាក
ការបៀតបៀនព្យាបាទ ។

អហំ អនីឃោហោមិ សូមឱ្យខ្ញុំព្រះករុណាប្រាសចាក
ការភ័យអន្តរាយទាំងឡាយ ។

សុខី អត្តានំ បរិហរាមិ រក្សាខ្លួនឱ្យមានសេចក្ដីសុខ
ជាដរាបទៅ ។

# ផ្សាយមេត្តាដល់សព្វសត្វ

សព្វេ សត្តា សត្វទាំងឡាយទាំងពួង ។

‹ ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យាទិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត ›

សព្វេ បាណា ពួកសត្វទាំងឡាយទាំងពួង ដែលមានខ្លួនប្រាណ ។

សព្វេ ភូតា ពួកភូតទាំងឡាយទាំងពួង ។

សព្វេ បុគ្គលា បុគ្គលទាំងឡាយទាំងពួង ។

សព្វេ អត្តភាវបរិយាបន្នា ពួកសត្វដែលទាក់ទង ដោយអត្តភាពទាំងឡាយទាំងពួង ។

សព្វេ អត្ថីយោ ពួកស្ត្រីទាំងឡាយទាំងពួង ។

សព្វេ បុរិសា ពួកបុរសទាំងឡាយទាំងពួង ។

សព្វេ អរិយា ព្រះអរិយទាំងឡាយទាំងពួង ។

សព្វេ ទេវា ទេវតាទាំងឡាយទាំងពួង ។

សព្វេ វិនិបាតិកា ពួកសត្វនរកទាំងឡាយទាំងពួង ។

អវេរា ហោន្តុ អព្យាបជ្ឈា ចូរប្រាសចាក នូវពៀរវេរា និង ការបៀតបៀនដល់គ្នានឹងគ្នា ។

អនីឃា សុខី អត្តានំ បរិហរន្តុ ជាអ្នកប្រាសចាក ឧបសគ្គភ័យអន្តរាយទាំងឡាយ រក្សាខ្លួននៅជាសុខ ។

# ផ្សាយមេត្តាចំពោះទិសទាំង១០

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងកើត កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសអាគ្នេយ៍កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងត្បូង កុំបី មានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសនីរតី កុំបី មានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសលិច កុំបី មានពៀរ នឹងគ្នា ចូរនៅជាសុខចុះ ។

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសពាយ័ព្យ កុំបី មានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងជើង កុំបីមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសឦសាន កុំបី មានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងលើ កុំបី មានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង ដែលនៅក្នុងទិសខាងក្រោម កុំបី មានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។

សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ សត្វទាំងឡាយទាំងពួង ចូរកុំមានពៀរនឹងគ្នា ចូរនៅជាសុខចុះ ។ ចូរកុំមានទុក្ខនឹងគ្នា ចូរកុំព្យាបាទនឹងគ្នា ចូរឱ្យជាអ្នកឥតមានសេចក្តីទុក្ខភ័យ ចូរឱ្យមានអាយុវែង ចូរកុំឱ្យមានរោគ ចូរឱ្យបានសម្រេច ដោយសម្បត្តិ ទាំងឡាយ ចូររក្សាខ្លួនឱ្យបានសេចក្តីសុខចុះ ។

ក្រោយពីផ្សាយមេត្តាគ្រប់ទិសទាំងពួងហើយ ក៏តាំងចាប់ផ្តើមការប្រតិបត្តិ តាំងចំណូលពេញចិត្តរបស់យើង តាមអារម្មណ៍របស់យើងដែលថ្មីកជំនាញ ដូចជាយកខ្យល់ដកដង្ហើមចេញចូលជាដើម គប្បីតាំងសតិកំណត់នូវការ ដកដង្ហើមឱ្យជំនាញ

ឃើញច្បាស់ នូវខ្យល់ចេញចូលឡើងចុះ ខ្យល់វែង ខ្យល់ខ្លី ខ្យល់គ្រោតគ្រាត ឬ ល្អិតសុខុម ដោយមានស្មារតីដឹងគ្រប់ចលនានៃខ្យល់ចេញចូល សភាវៈដែលមកប៉ះទង្គិច ខាងក្រៅក្ដី ខាងក្នុងក្ដី គប្បីមានសតិ កំណត់ដឹងឱ្យទាន់ជាបច្ចុប្បន្នក្នុងអារម្មណ៍ដែលមកប៉ះទង្គិច គឺការ កើតរលត់នៃអារម្មណ៍ដែលជារូបធម៌ នាមធម៌ ។ លោកអ្នក ប្រតិបត្តិ ត្រូវខំព្យាយាមហ្វឹកកំណត់នូវសតិស្មារតីឱ្យដឹងទាន់ ឱ្យជំនាញក្នុងអារម្មណ៍ដែលយើងកំពុងហ្វឹកចំរើនជារៀងរាល់ថ្ងៃ តាមការកំណត់របស់គ្រូអាចារ្យ ។

## វិបស្សនាភូមិ ៦ សង្ខេប

### លោកអ្នកបដិបត្តិត្រូវចេះវិបស្សនាភូមិ ៦ សង្ខេបនេះ

១- ខន្ធ ៥ ( ខន្ធ ប្រែថា កង គំនរ )

២- អាយតនៈ១២ (អាយតនៈ ប្រែថា ទីកន្លែងដែលតភ្ជាប់នូវអារម្មណ៍ជាកន្លែងកើតនូវអារម្មណ៍ ដឹងនូវអារម្មណ៍) ។

៣- ធាតុ ១៨ ( គឺសភាវៈដែលទ្រទ្រង់ទុក ) ។

៤- ឥន្ទ្រិយ ២២ ( សភាវៈជាធំនៃខន្ធ ) ។

៥- អរិយសច្ច ៤ ( សេចក្តីពិតដ៏ប្រសើរ ) ។

៦- បដិច្ចសមុប្បាទ ១២ ( សភាវៈដែលមានការ ប្រទាក់ ប្រទងគ្នា ប្រជុំព្រមជាមួយហេតុ នឹងផល ) ។

## បរមត្ថធម៌ ៤ ប្រការ

១- ចិត្ត ៨៩ ឬ ១២១ ដួង ( ដឹងនូវអារម្មណ៍ ) ។

២- ចេតសិក ៥២ ( សភាវៈកើតរលត់ជាមួយចិត្ត ) ។

៣- រូប ២៤ ( គឺមហាភូតរូប ៤, ឧបាទាយរូប ២៤ ) សភាវៈ ដែលបែកធ្លាយវិនាសហៅថា រូប ។

៤- និព្វាន ១ ។

## រួមជាបរមត្ថធម៌ ៤ ដោយសង្ខេប

### ភូមិទី ១ ខន្ធ ៥ ព្រមដោយសេចក្តីអធិប្បាយសង្ខេប

១- រូបខន្ធ មានកិរិយាបែកធ្លាយជាផល ។

២-　វេទនាខន្ធ　មាននាទីសោយនូវអារម្មណ៍　ទំពារស៊ីនូវអារម្មណ៍ ។

៣-　សញ្ញាខន្ធ　មានកិរិយាចាំនូវអារម្មណ៍ ។

៤-　សង្ខារខន្ធ　មាននាទីតាក់តែងនូវអារម្មណ៍　របនានូវអារម្មណ៍ ។

៥-　វិញ្ញាណខន្ធ　មាននាទីទទួលដឹងនូវអារម្មណ៍ ។

សង្គ្រោះបរមត្ថធម៌ទាំង ៤ ចូលក្នុងខន្ធ ៥

យករូបបរមត្ថ ២៨ ជារូបខន្ធ ។ យកវេទនាចេតសិក ១ មកជាវេទនាខន្ធ ។ យកសញ្ញាចេតសិក ១ មកជាសញ្ញាខន្ធ ។ យកសង្ខារចេតសិក ដែលនៅសល់ ៥០ មកជាសង្ខារខន្ធ ។ យកចិត្ត ៨៩ ឬ ១២១ មកជាវិញ្ញាណខន្ធ ។

## ខន្ធ ទាំង ៥ នេះ

### អ្វីជារូបធម៌ អ្វីជានាមធម៌

១-　រូបខន្ធ ជារូបធម៌ ( ជារូប )

២- វេទនាខន្ធ ជានាមធម៌ចេតសិក

៣- សញ្ញាខន្ធ ជានាមធម៌ចេតសិក > ជានាមធម៌

៤- សង្ខារខន្ធ ជានាមធម៌ចេតសិក

៥- វិញ្ញាណខន្ធ ជានាមធម៌ គឺចិត្ត

នាមធម៌ជាចេតសិក ៣ > ចាត់ជានាមធម៌

ជានាមធម៌ ជាចិត្ត ១

កាលបើរួមនាមធម៌ជាចេតសិក ៣ ជាមួយនាមធម៌ចិត្ត ១ ជានាមធម៌ ខន្ធ ៤ រូបខន្ធ ១ ជារូបធម៌ ។ ខន្ធទាំង ៥ ពោលដោយ ខ្លី គឺរូបធម៌ និង នាមធម៌ ត្រឹមពីរបទប៉ុណ្ណេះឯង ដោយសង្ខេប ។

## ភូមិទី ២ អាយតនៈ ១២

១- ចក្ខាយតន អាយតនៈគឺភ្នែក ។

២- សោតាយតន អាយតនៈគឺត្រចៀក ។

៣- ឃានាយតន អាយតនៈគឺច្រមុះ ។

៤- ជិវ្ហាយតន អាយតនៈគឺអណ្តាត ។

៥- កាយាយតន អាយតនៈគឺកាយ ។

៦- មនាយតន អាយតនៈគឺចិត្ត ។

៧- រូបាយតន អាយតនៈគឺរូប ។

៨- សទ្ទាយតន អាយតនៈគឺសម្លេង ។

៩- គន្ធាយតន អាយតនៈគឺក្លិន ។

១០- រសាយតន អាយតនៈគឺរស ។

១១- ផោដ្ឋព្វាយតន អាយតនៈគឺសម្ផស្សៈ ។

១២- ធម្មាយតន អាយតនៈ គឺ ចិត្តនិងចេតសិកអារម្មណ៍របស់ផ្លូវចិត្ត ។

អាយតនៈទាំង ១២ នេះចាត់ជាខាងក្នុង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ចាត់ជាអាយតនៈ ។

ខាងក្រៅ ៦ គឺ រូប សម្លេង ក្លិន រស សម្ផស្សការប៉ះពាល់នឹងអារម្មណ៍នឹកគិតតាមផ្លូវចិត្ត ។

អាយតនៈទាំង ១២ នេះចាត់ជារូបធម៌ នាមធម៌ដូចតទៅនេះ %

ភ្នែក និង រូប ( ពណ៌ ) ជារូបធម៌ ឃើញឬដឹងជានាមធម៌

ត្រចៀក និង សម្លេង ជារូបធម៌ បានឮសម្លេងជានាមធម៌

ច្រមុះ និង ក្លិន ជារូបធម៌ សេចក្តីដឹងនូវក្លិនជានាមធម៌

អណ្តាត និង រស ជារូបធម៌ សេចក្តីដឹងនូវរសជានាមធម៌

កាយ នង តរិយាបថផ្លាស់ប្តូរប៉ះពាល់ជារូប សេចក្តីដឹងការប៉ះពាល់ ក្តៅត្រជាក់ជានាមធម៌ ។

## ភូមិទី ៣ ធាតុ ១៨

## ចែកចេញជា ៣ ប្រភេទ

## ធាតុសម្រាប់ទទួល

១- ចក្ខុធាតុ បានដល់ភ្នែក ជារូប ។

២- សោតធាតុ បានដល់ត្រចៀក ជារូប ។

៣- ឃានធាតុ បានដល់ច្រមុះ ជារូប ។

៤- ជិវ្ហាធាតុ បានដល់អណ្តាត ជារូប ។

៥- កាយធាតុ បានដល់កាយ ជារូប ។

៦- មនោធាតុ បានដល់ចិត្ត ជានាម ។

## ធាតុខាងក្រៅសម្រាប់ប៉ះទង្គិច

៧- រូបធាតុ បានដល់នូវរូប ( ពណ៌ ) ជារូប ។

៨- សទ្ទធាតុ បានដល់សម្លេង ជារូប ។

៩- គន្ធធាតុ បានដល់ក្លិន ជារូប ។

១០- រសធាតុ បានដល់ឱជារស ជារូប ។

១១- ផោដ្ឋព្វធាតុ បានដល់ការប៉ះពាល់ ជារូប ។

១២- ធម្មធាតុ បានដល់អារម្មណ៍ខាងផ្លូវចិត្តជានាម ។

## ធាតុសម្រាប់ទទួលដឹង

១៣- ចក្ខុវិញ្ញាណធាតុ បានដល់ចក្ខុវិញ្ញាណ ដែលឃើញរូប ឃើញពណ៌ ជានាមធម៌ ។

១៤- សោតវិញ្ញាណធាតុ បានដល់សោតវិញ្ញាណ ដែលសម្រាប់ឮនូវសម្លេង ជានាមធម៌ ។

១៥- **ឃានវិញ្ញាណធាតុ** បានដល់ឃានវិញ្ញាណ ដែលសម្រាប់ដឹងនូវក្លិន ជានាមធម៌ ។

១៦- **ជិវ្ហាវិញ្ញាណធាតុ** បានដល់ជីវ្ហាវិញ្ញាណ ដែលការ សម្រាប់ដឹងនូវឱជារសផ្សេងៗ ជានាមធម៌ ។

១៧- **កាយវិញ្ញាណធាតុ** បានដល់កាយវិញ្ញាណ ដែលសម្រាប់ដឹងនូវការប៉ះទង្គិច ក្តៅ ត្រជាក់ជានាមធម៌ ។

១៨- **មនោវិញ្ញាណធាតុ** បានដល់មនោវិញ្ញាណ ភាវៈដឹងនូវការនឹកគិតផ្សេង ៗ ជានាមធម៌ ។

ធាតុដែលចំពោះតែរូបមាន ១០ ធាតុចំពោះតែនាមមាន ៧ ដែលកើតទាំងរូបទាំងនាមមាន ១ កាលបើរួមធាតុទាំង ១៨ ហើយ បែងជាពីរប្រភេទគឺ រូបធាតុ ១ និងនាមធាតុ ១ ឬរូបធម៌ ១ និងនាមធម៌ ១ ។

## ភូមិទី ៤ ឥន្ទ្រិយ ២២ ( ភាវៈធាធំ )

១- **ចក្ខុន្ទ្រីយ** ភាវៈជាធំគឺភ្នែក (រូប) ឃើញរូប ។

២- **សោតិន្ទ្រីយ** ភាវៈជាធំគឺត្រចៀក (រូប) ឮសម្លេង ។

៣- ឃានិន្ទ្រីយ ភាវៈជាធំគឺច្រមុះ (រូប) ដែលធុំក្លិន ។

៤- ជិវ្ហិន្ទ្រីយ ភាវៈជាធំគឺអណ្តាត (រូប) ដែលដឹងនូវរស ។

៥- កាយិន្ទ្រីយ ភាវៈជាធំគឺកាយ (រូប) សម្រាប់កាន់ដឹងនូវក្តៅ ត្រជាក់ រឹង ទន់ ។

៦- ឥត្ថិន្ទ្រីយ ភាវៈជាធំនៃស្រ្តី (រូប) ។

៧- បុរិសិន្ទ្រីយ ភាវៈជាធំនៃបុរស (រូប) ។

៨- ជីវិតិន្ទ្រីយ ភាវៈជាធំនៃជីវិតដែលទ្រទ្រង់ នូវរូបនាមឱ្យ តាំងនៅជាប្រក្រតី (បានទាំងរូបទាំងនាម) ។

៩- មនិន្ទ្រីយ ភាវៈជាធំនៃចិត្ត ក្នុងការនឹកគិត (នាម) ។

១០- សុខិន្ទ្រីយ ភាវៈជាធំគឺសេចក្តីសុខ (នាម) ។

១១- ទុក្ខិន្ទ្រីយ ភាវៈជាធំគឺសេចក្តីទុក្ខ (នាម) ។

១២- សោមនស្សិន្ទ្រីយ ភាវៈជាធំនៃការសប្បាយចិត្ត រីករាយចិត្ត (នាម) ។

១៣- ទោមនស្សិន្ទ្រីយ ភាវៈជាធំគឺសេក្តីទុក្ខ ពិបាកចិត្ត ចង្អៀតចង្អល់ចិត្ត (នាម) ។

១៤- ឧបេក្ខិន្ទ្រិយ ភាវៈជាធំនៃការព្រងើយកន្តើយ ជាកណ្តាល ៗ (នាម) ។

១៥- សទ្ធិន្ទ្រិយ ភាវៈជាធំនៃការជឿ (នាម) ។

១៦- វីរិយិន្ទ្រិយ ភាវៈជាធំនៃសេចក្តីព្យាយាម (នាម) ។

១៧- សតិន្ទ្រិយ ភាវៈជាធំនៃសតិរលឹកបាន (នាម) ។

១៨- សមាធិន្ទ្រិយ ភាវៈជាធំគឺសមាធិដម្កល់ចិត្តនឹងនៅក្នុងអារម្មណ៍ (នាម) ។

១៩- បញ្ញិន្ទ្រិយ ភាវៈជាធំគឺបញ្ញាចេះដឹង (នាម) ។

២០- អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ភាវៈជាធំនៃការដឹងច្បាស់ នូវ សោតាបត្តិមគ្គញ្ញាណ (នាម) ។

២១- អញ្ញិន្ទ្រិយ ភាវៈជាធំ នៃការដឹងច្បាស់នូវសោតាបត្តិផលញ្ញាណ ។

សកទាគាមិមគ្គញ្ញាណ សកទាគាមិផលញ្ញាណ

អានាគាមិមគ្គញ្ញាណ អានាគាមិផលញ្ញាណ

អរហត្តមគ្គញ្ញាណ ជានាមធម៌ ។

២២- អញ្ញាតាវិន្ទ្រិយ

ភាវៈជាធំនៃការដឹងច្បាស់នូវទីបញ្ចប់ នៃព្រហ្មចរិយៈ គឺ អរហត្តផលញ្ញាណ ( នាម ) ។

ឥន្ទ្រិយទាំង ២២ នេះចាត់ជារូបធម៌ ៧ , ជានាម ១៤ , បានទាំងរូបធម៌ - នាមធម៌ ១ , រូបធម៌នាមធម៌នេះហើយ ដែលនាំមកនូវអារម្មណ៍របស់វិបស្សនា ព្រោះជាធម៌សំខាន់ក្នុង ការពិសោធន៍ សិក្សាដោយបញ្ញាឱ្យឃើញច្បាស់តាមភាវៈពិត ។

## ភូមិទី ៥ អរិយសច្ច ៤

១- ទុក្ខអរិយសច្ច អង្គនៃធម៌បានដល់រូប ២៨ ចិត្ត ៨១ ចេតសិក ៥១ គឺរូបនាម ( វៀរលែងតែលោភៈ ១ ចេញ ) ជាទុក្ខពិតប្រាកដ ។

២- សមុទយអរិយសច្ច អង្គនៃធម៌បានដល់លោភៈ ចេតសិក ១ ជាមូលហេតុនាំឱ្យកើតសេចក្តីទុក្ខពិតប្រាកដ ។

៣- និរោធអរិយសច្ច  អង្គនៃធម៌បានដល់ ព្រះនិព្វាន ដែលជាទីរំលត់នូវសេចក្តីទុក្ខពិតប្រាកដ ។

៤- មគ្គអរិយសច្ច  អង្គនៃធម៌បានដល់មគ្គអង្គ ៨ ដែលជាផ្លូវនាំទៅកាន់ទីរំលត់ទុក្ខដោយពិតប្រាកដ មគ្គអង្គ ៨ នោះគឺ ប្រាជ្ញាយល់ឃើញត្រូវ ១, សេចក្តីត្រិះរិះត្រូវ១, ពោលវាចាត្រូវ១, ការងារត្រូវ ១, ចិញ្ចឹមជីវិតត្រូវ ១ , សេចក្តីព្យាយាមត្រូវ ១, សេចក្តីរលឹកត្រូវ ១, ការដម្កល់ចិត្តឱ្យនឹងត្រូវក្នុងអារម្មណ៍ តែមួយ ១ ។

ព្រះយោគាវចរ អ្នកប្រតិបត្តិដើម្បីឱ្យឃើញ ការដឹងពិតក្នុងសច្ចះធម៌ទាំង ៤ នេះត្រូវខំព្យាយាមចំរើនកម្មដ្ឋាន មានវិបស្សនាកម្មដ្ឋានជាដើម ឱ្យបានច្រើន មានការកំណត់រូបនាមក្នុង ខន្ធទាំង ៥ មានរូបជាដើម ដែលប្រែប្រួលទៅតាមពេលវេលា មានក្តៅ ត្រជាក់ ដែលមកប៉ះទង្គិច ធ្វើឱ្យវិនាសដល់នូវសេចក្តីទុក្ខ ដែលយើងអ្នកប្រតិបត្តិត្រូវតែកំណត់ដឹងដោយប្រាជ្ញាលះបង់ហេតុ ដែលនាំឱ្យកើតសេចក្តីទុក្ខ មានលោភៈ តណ្ហា

ជាដើម ធ្វើឱ្យឃើញច្បាស់នូវទីរំលត់ទុក្ខគឺព្រះនិព្វាន ។ ព្យាយាមចំរើនឱ្យបានច្រើន រឿយៗនូវមគ្គទាំង ៨ ដែលជាផ្លូវកាប់ឆ្ការនូវកិលេសធម៌ ធ្វើដំណើរទៅកាន់ទីរំលត់ទុក្ខ ។

## ភូមិទី ៦ បដិច្ចសមុប្បាទ ១២

ធម៌ជាបច្ច័យទាក់ទងគ្នាដូចជាច្រវាក់កង់

១- ***អវិជ្ជា*** ការមិនដឹង ( គូគ្នានឹងមោហៈ ការវង្វេង ) មិនស្គាល់មិនយល់នូវការពិត ( ជានាម ) ។

២- ***សង្ខារ*** ការតាក់តែង ការរចនាឱ្យកើតឡើង ជានាម បានដល់សង្ខារ ៣ ឬសង្ខារ ៦, ជាបរមត្ថបានដល់វចនា ២៩ (ក្នុងអកុសល ១២ មហាកុសល ៨ មហគ្គកុសល ៩ ) ជាសង្ខារ ។

៣- ***វិញ្ញាណ*** ការដឹង (ចិត្ត) ជានាម ។

៤- ***នាមរូប*** គឺរូប ២៨ , ***ចិត្ត*** ៨៩ ដួង (ជារូបនាម) ។

៥- ***សឡាយតន*** កន្លែងកើតនូវអារម្មណ៍ គឺអាយតនៈទាំង ១២ ខាងក្នុង ៦ , ខាងក្រៅ ៦ , ( ជារូបធម៌ ជានាមធម៌ ) ។

៦- ***ផស្សៈ*** ការប៉ះពាល់ត្រូវនូវអារម្មណ៍ បានដល់ផស្សចេតសិក ជានាមធម៌ ។

៧- ***វេទនា*** ការទទួលនូវអារម្មណ៍ ឬទំពារស៊ីនូវអារម្មណ៍ បានដល់វេទនាចេតសិក ជានាមធម៌ ។

៨- ***តណ្ហា*** ការចង់បាននេះ ចង់បាននោះមិនចេះឆ្អែតមិនចេះល្មម បានដល់លោភៈចេតសិក ជានាមធម៌ ។

៩- ***ឧបាទាន*** ការប្រកាន់ភ្ជាប់ថាជារបស់ខ្លួន បានដល់លោភៈ ចេតសិក ជានាមធម៌ ។

១០- ***ភព*** ជាទីកើត ជាទីអាស្រ័យនៅ គឺភពទាំង ៣ មានចេតនាចេតសិក ជាតួកម្មរចនា ជានាមធម៌ ។

១១- ***ជាតិ*** ការកើត បានដល់វិបាកបដិសន្ធិ ជាបុណ្យខ្លះ ជាបាបខ្លះ ជាអ្នករចនារូបនាម ។

១២- ***ជរាមរណៈ*** ការចាស់ជរា និងសេចក្ដីស្លាប់ ដែលជាផលចុងក្រោយនៃការកើតរបស់រូបនាម ។

បដិច្ចសមុប្បាទទាំង ១២ នេះជាបច្ច័យទាក់ទងដល់គ្នានឹង គ្នា ដើម្បីយល់ច្បាស់នូវធម៌នេះ ហើយយើងត្រូវហ្វឹកហាត់កំណត់ ក្នុងសតិប្បដ្ឋានវិធី គឺការហ្វឹកស្មារតីរលឹកឱ្យទាន់ដឹងនូវអារម្មណ៍ ជាបច្ចុប្បន្នធម៌ អ្វីដែលកំពុងកើតចំពោះមុខភ្លាម ៗ មិនឱ្យកន្លង ផុតទៅ ឬមិនឱ្យសតិស្មារតីរលឹកកំណត់ទុកដោយមិនទាន់ មានអារម្មណ៍មកប៉ះទង្គិច វិធីកំណត់សតិជាបច្ចុប្បន្នធម៌របស់ រូបនាម ដូចនេះ :

១- ***តាមផ្លូវភ្នែក*** ខណៈឃើញរូបគឺយកសតិមកដាក់នឹងភ្នែកកំណត់ថាពណ៌ជារូប ការដឹងឃើញនូវពណ៌នោះជានាម ។

២- ***តាមផ្លូវត្រចៀក*** ខណៈឮសម្លេងយកសតិតាំងទុកនឹងត្រចៀក កំណត់ថាសម្លេងជារូប ការដឹងបានឮសម្លេងជានាម ។

៣- ***តាមផ្លូវច្រមុះ*** ខណៈដែលបានប៉ះទង្គិចនូវក្លិន ត្រូវយកសតិស្មារតី មកដាក់ត្រង់ច្រមុះ កំណត់ថាក្លិនជារូប ការដឹងនូវក្លិន

នោះជានាម ។

៤- ***តាមផ្លូវអណ្តាត*** ខណៈអណ្តាតប៉ះនូវរសត្រូវយកសតិ (រលឹក)នូវនឹងអណ្តាត កំណត់ថា រសជាតិ ( ប្រៃ ល្វីង ជូរ ចត់ ផ្អែម ) ជារូប ការដឹងនូវរសជាតិជានាម ។

៥- ***តាមផ្លូវកាយ*** ខណៈកាយប៉ះទង្គិច ( មានរឹង ទន់ ក្តៅ ត្រជាក់ )ត្រូវយកសតិមកតាំងទុកនឹងកាយ, ត្រង់ស្បែកដែលប៉ះពាល់ ក្តៅ ត្រជាក់ កំណត់ថា ក្តៅត្រជាក់ ជារូប សេចក្តីដឹងក្តៅត្រជាក់ជានាម រឹងទន់ជារូប ការដឹងថារឹងទន់ជានាម ។

៦- ***តាមផ្លូវចិត្ត*** ខណៈដែលចិត្តកំពុងនឹកគិត ត្រូវយកសតិស្មារតីកំណត់ទុកក្នុងចិត្ត ដោយកំណត់ថា ហទយ (បេះដូង) ជារូប ការដឹងនូវចិត្តដែលកំពុងនឹកគិត ទៅកាន់ទីដទៃ ជានាម នឹងកំណត់ សតិស្មារតី ឱ្យដឹងទាន់គ្រប់ឥរិយាបថ ទាំងបួន មានការដើរ ឈរ អង្គុយ ដេក នឹងចលនាផ្សេង ៗ ដែលយើងធ្វើដោយដៃ មានការលើកដៃលើកជើងជាដើម គឺមានសតិរលឹកឱ្យទាន់គ្រប់សកម្មភាព ដូចជា ការឈរជារូប

ដឹងថាឈរជានាម , ការឈានដើរជារូប ដឹងថាឈានជើងជានាម, ការអង្គុយជារូប ដឹងរូបអង្គុយជានាម , រូបដេកជារូប ការដឹងនូវរូបដែលកំពុងដេកជានាម គ្រវាសឆ្វេង ស្តាំជារូប ដឹងថាគ្រវាសទៅមកជានាម , ការបោះចុះឡើងជារូប សេចក្តីដឹងការបោះចុះឡើងជានាម , អាការៈចុះឡើងជារូប សេចក្តីដឹងអាការៈចុះឡើងនោះៗ ជានាម , ការឈឺចាប់ជានាម ការកង្វល់ចិត្ត ការវើរវាយអណ្តែតអណ្តូងជានាម , ការរីករាយសប្បាយចិត្ត ការពិបាកចិត្ត សេចក្តីទុកត្រប់យ៉ាងនេះ កើតឡើងព្រោះអាស្រ័យវេទនាជាអ្នកទទួលដឹងជាទុក្ខខ្លះ ជាសុខខ្លះ ជាសោមនស្សចិត្តខ្លះ ជាទោមនស្សចិត្តខ្លះដែលនាមធម៌ទាំងអស់។

រូមន័យ ការកំណត់ហ្វឹកសតិនេះ ត្រូវកំណត់ឱ្យកើតជាអារម្មណ៍តែមួយ , មិនគប្បីកំណត់ឱ្យជាអារម្មណ៍គូរ ឬច្រើនហួសប្រមាណ ដែលយើងមិនអាចកំណត់ទាន់ ហើយជាហេតុធ្វើឱ្យចិត្ត រួចថយនូវការព្យាយាម ដូច្នេះយើងត្រូវហ្វឹកនូវអារម្មណ៍ណាមួយឱ្យជំនាញ ឱ្យឃើញច្បាស់សភាវៈធម៌ដែល

កើតជាបច្ចុប្បន្ន ភ្លាមៗ ជាសន្តតិរូបនាម គឺត្រូវការឱ្យស្គាល់ច្បាស់នូវរូបនាម ត្រង់កន្លែងដែលរូបនាម កំពុងប្រាកដកើតនោះឯង មិនមែនទៅរករូបនាម អ្វីដទៃក្រៅពីក្នុងខ្លួនយើងនោះទេ ដូចជាការឈានដើរជារូប ដឹងការឈានដើរទៅជានាម គឺឱ្យសតិស្មារតីរលឹកតាម នូវរូបដែល កំពុងឈានទៅនោះ គឺសភាវៈកើតក្នុងខណៈនោះយ៉ាងដូចម្ដេច អាការៈដែលដឹងថាជើងកំពុងឈានទៅនោះជានាម ។ ខណៈកំពុងឈានទៅនោះមានសេចក្ដីដឹងព្រមទៅជាមួយ ហើយត្រូវពិនិត្យនូវសភាវៈនៃការដឹងដែលកើតឡើងហើយរលត់ទៅវិញ កាលបើពិចារណានូវសភាវៈធម៌ ដែលកំពុងកើតជាបច្ចុប្បន្ននេះ ជាញឹកញយ ៗ ឱ្យជាប់គ្នាដោយមិនដាច់រយៈ ដូចច្រវាក់នៃកង់ ដែលមានចលនាវិលទៅ ប្រព្រឹត្តទៅដោយមិនដាច់រយៈគ្នា ក្នុងខណៈដែលសតិស្មារតីយើងតាំងនៅក្នុងអារម្មណ៍ជាបច្ចុប្បន្ន ហើយយើងអាចឃើញច្បាស់នូវសភាវៈធម៌ គឺ សេចក្ដីពិតក្នុងអរិយសច្ចមានទុក្ខសច្ចៈនិងសភាវៈប្រែប្រួលមិនទៀងទាត់ ដែលកើត

រលត់តាមអារម្មណ៍និមួយៗ ដោយពិតតាមន័យពុទ្ធភាសិត ដែលព្រះមានព្រះភាគ ទ្រង់សំដែងបញ្ជាក់១បទថា "របស់ណា ដែលកើតឡើងជាធម្មតា របស់ទាំងអស់នោះនឹងរលត់ បែក ធ្លាយទៅវិញជាធម្មតា" មិនថាអារម្មណ៍ផ្លូវភ្នែក ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្ត ត្រូវព្យាយាម ហ្វឹកហាត់សតិស្មារតីឱ្យរឹងមាំឱ្យជំនាញក្នុងទ្វារទាំង៦នេះដែលជា កន្លែងរបស់វិបស្សនាញាណ និងជាកញ្ចក់សម្រាប់ឆ្លុះ ឱ្យឃើញ នូវសភាវៈពិត ដើម្បីទំលាយបង់នូវសេចក្តីលោភ សេចក្តី ក្រោធខឹង និងការវង្វេងមិនដឹងការពិត និងសេចក្តីប្រមាទ ឱ្យអស់ ពីចិត្តគំនិត ធ្វើចិត្តឱ្យស្អាតបរិសុទ្ធ មានសតិស្មារតី រឹងមាំ មានឥន្ទ្រីយចាស់ក្លា និងបញ្ញាមុះមុតក្នុងការវិនិច្ឆ័យ នូវ សភាវៈធម៌ ដែលកើតឡើង ថានេះជាធម៌ នេះជាកិលេស ដែលត្រូវលះមិនត្រូវកាន់យកដូច្នេះជាដើម ។ ដែលលោកអ្នក ប្រតិបត្តិត្រូវតាំង សេចក្តីព្យាយាមឱ្យខ្លាំងក្លា មិនត្រូវតាំងនូវ ក្នុងសេចក្តី ប្រមាទឡើយ ។

# ឥន្ទ្រីយទី ៥ (ភាវៈជាធំ)

១- សទ្ធិន្ទ្រីយ សេចក្ដីជឿ បានដល់សទ្ធាចេតសិក ។

២- វីរិយិន្ទ្រីយ សេចក្ដីព្យាយាម បានដល់វីរិយៈចេតសិក ។

៣- សតិន្ទ្រីយ សេចក្ដីរលឹក បានរលឹកទាន់ បានដល់សតិចេតសិក ។

៤- សមាធិន្ទ្រីយ សេចក្ដីតាំងចិត្តយ៉ាងមាំ បានដល់ឯគ្គតាចេតសិក ។

៥- បញ្ញិន្ទ្រីយ បញ្ញាចាក់ធ្លុះស្គាល់ច្បាស់ នូវសភាវៈគ្រប់យ៉ាង បានដល់បញ្ញាចេតសិក យោគាវចរអ្នកប្រតិបត្តិ ត្រូវឧស្សាហ៍ព្យាយាម ហ្វឹកហាត់អប់រំបារមីឥន្ទ្រីយទាំង៥នេះឱ្យចាស់ក្លា មានកម្លាំងរួមជាមួយវិបស្សនាផង ដែលហៅថាពលៈធម៌ មានន័យថា ធម៌ជាកម្លាំងដល់គ្នានឹងគ្នា ដើម្បីធ្វើឱ្យវិបស្សនាញាណ មានកម្លាំងខ្លាំងឡើង ជាប្រភពធ្វើឱ្យសតិស្មារតី រលឹកដឹងចំពោះ រូបធម៌ នាមធម៌ ជាប់បន្តគ្នាជាសន្តតិអារម្មណ៍ គឺអារម្មណ៍មិនដាច់ រយៈពីគ្នា

ជាបច្ចុប្បន្នអារម្មណ៍មិនឱ្យហួសទៅជាបញ្ញត្តិអារម្មណ៍ អតីតៈ ឱ្យដឹងជាសភាវៈធម៌ជាបច្ចុប្បន្នភ្លាម ៗ មិនមែនជាអតីតៈ មិនមែនជាអនាគតតាមផ្លូវភ្នែក តាមផ្លូវត្រចៀក តាមផ្លូវច្រមុះ តាមផ្លូវអណ្តាត តាមផ្លូវកាយ តាមផ្លូវចិត្ត ជាសភាវៈរូប នឹងនាម ដែលកើតហើយរលត់ទៅវិញព្រមៗ គ្នាគ្រប់ខណៈ ។

ការហ្វឹកហាត់សតិបែបនេះ ដរាបដល់បញ្ញាញាណចាស់ក្លាចិត្តកន្លងផុតចាកពី នីវរណៈកិលេសដែលជាគ្រឿងរារាំងចិត្ត មិនឱ្យចាប់យកសេចក្តីល្អបរិសុទ្ធិបាន និងកន្លងផុតចាកនិមិត្ត (សភាវៈ បញ្ឆោតចិត្តឱ្យជាប់ជំពាក់ ) បានហើយ ទើបហៅថាពលវៈវិបស្សនាឃើញជាក់ច្បាស់នូវរូបនាម គឺឃើញច្បាស់ ដឹងស្គាល់នូវសភាវៈកើត នឹងរលត់ ៗ កើត ស្លាប់ ៗ ជាបន្តបន្ទាប់មិនដាច់រយៈគ្រប់ខណៈចិត្តដែលប៉ះទង្គិចនូវអារម្មណ៍ទាំងឡាយ ។

ដូច្នេះយោគាវចរអ្នកប្រតិបត្តិត្រូវប្រយ័ត្នអន្តរាយ ដោយកិលេសរបស់វិបស្សនា (វិបស្សនូកិលេស) ទាំង ១០ យ៉ាង ។ ត្រង់ន័យពុទ្ធភាសិតថា ឱភាសោ បីតិ បស្សទ្ធិ

អធិមោក្ខោ ច បគ្គហោ សុខំ ញាណុបដ្ឋានំ ឧបេក្ខា ច និកន្តិ ច គឺឱភាសៈ ១, បីតិ ១, បស្សទ្ធិ ១, អធិមោក្ខៈ ១, បគ្គហ ១, សុខៈ ១, ញាណៈ ១, ឧបដ្ឋាន ១, ឧបេក្ខា ១, និកន្តិ ១ ។ សភាវៈ ១០ យ៉ាងនេះជាតួអន្តរាយរបស់វិបស្សនាញាណ លោកអ្នកប្រតិបត្តិត្រូវប្រយ័ត្ន ។

១- *ឱភាសៈ* ពន្លឺកើតឡើង មានសេចក្តីពេញចិត្ត ។

២- *បីតិ* សេចក្តីឆ្អែតចិត្តពេញចិត្តហួសពេក ។

៣- *បស្សទ្ធិ* សេចក្តីស្ងប់កាយស្ងប់ចិត្ត ។

៤- *អធិមោក្ខៈ* ចិត្តបង្អោនជឿស៊ប់ មិនកម្រើកក្នុងអារម្មណ៍ហួសពេក ។

៥- *បគ្គាហៈ* មានសេចក្តីព្យាយាមដ៏ខ្លាំងក្លា ។

៦- *សុខៈ* មានសេចក្តីសុខក្រៃលែងមិនធ្លាប់មាន ។

៧- *ញាណៈ* ការពិចារណា ដឹងច្បាស់នូវអារម្មណ៍ ។

៨- *ឧបដ្ឋានៈ* ការដែលមានសតិស្មារតីដឹងច្បាស់ តាំងនៅមាំដោយល្អខុសប្រក្រតី ។

៩- ***ឧទ្ធច្ចៈ*** ចិត្តអស់កង្វល់នៅស្ងៀម ព្រងើយកន្តើយ ។

១០- ***និកន្តិ*** គឺមានចិត្តត្រេកអរ ជាប់ជំពាក់នូវអារម្មណ៍ទាំង៩ ខាងលើនេះ ដែលធ្វើឱ្យចិត្តភ្លេចតាមកំណត់ដឹង នូវអារម្មណ៍ ដែលកំពុងកើតរលត់ទៅទៀតទើបឈ្មោះថាវិបស្សនូបកិលេស ។ កាលបើមានភាវៈធម៌បែបនេះកើតមាន អស់លោកអ្នកប្រតិបត្តិ ទាំងឡាយត្រូវប្រយ័ត្ន កុំឱ្យចិត្តភ្លើចាប់យក ឬត្រេកអរនូវ សភាវៈ និមិត្តបែបនេះឱ្យសោះ ព្រោះមិនមែនជា អរិយមគ្គធម៌ជាន់ខ្ពស់ នោះទេ ។ ព្រោះវាជាសហជាតិធម៌ ដែលកើតឡើងហើយរលត់ ទៅវិញជាធម្មតា បើយើងស្រឡាញ់ ជាប់ជំពាក់ត្រឹមនេះ យើងមិនអាចឆ្លងទៅកាន់លោកុត្តរៈធម៌ ដែលជាធម៌ របស់អរិយដោយពិតប្រាកដបានទេ ដូច្នេះយើង ត្រូវតែមានសតិស្មារតីកំណត់ តាមមើលតែសកម្មភាព កើតរលត់ របស់អារម្មណ៍ គឺរូបនាម ដែលជាធម្មជាតិ បរមត្ថល្អិតសុខុម ។

សំណួរដោយសង្ខេប ក្នុងបដិបទារបស់ព្រះយោគាវចរ ដែល កំពុងចំរើនវិបស្សនាកម្មដ្ឋាន ។

*សំនួរ.* អ្នកចំរើនសតិ ហ្វឹកសតិ មានអ្វីជាផ្លូវដើររបស់សតិ ក្នុងពេលចំរើន នឹងក្នុងពេលទាំងពួង ?

*ចំលើយ.* រូបនាម គឺសភាវៈធម៌ដែលជាបច្ចុប្បន្នអារម្មណ៍ ជាផ្លូវ ដើរ របស់សតិ ។

*សំនួរ.* អ្វីហៅថា វិបស្សនា ?

*ចំលើយ.* គឺសេចក្តីដឹងច្បាស់ ឃើញច្បាស់តាមសេចក្តីពិត របស់អារម្មណ៍ជា អនិច្ចំ ទុក្ខំ អនត្តា ហៅថាវិបស្សនា ។

*សំនួរ.* អ្វីដែលជាតួរបស់វិបស្សនា ?

*ចំលើយ.* បញ្ញាញាណ ជាតួរបស់វិបស្សនា ។

*សំនួរ.* អ្នកណាដែលជាអ្នកចំរើនវិបស្សនា ?

*ចំលើយ.* សតិជាអ្នកចំរើនវិបស្សនា

សតិចាប់យករូបនាម

មកជាអារម្មណ៍យករូបនាម ជាផ្លូវដើរ ។ ឈ្មោះថាសតិជាអ្នកចំរើន វិបស្សនា ដូចអ្នកដើរត្រូវអាស្រ័យផ្លូវដើរដូច្នេះឯង ។

លោកអ្នកសិក្សាចំរើនវិបស្សនា ក៏ត្រូវអាស្រ័យចំរើនដោយផែនទី គឺវិបស្សនាភូមិទាំង ៦ មានខន្ធ ៥ ។ *អាយតនៈ ១២ , ធាតុ ១៨ , ឥន្ទ្រិយ ២២ , អរិយសច្ចៈ ៤ , បដិច្ចសមុប្បាទ ១២* ទាំងអស់នេះជាផែនទីសំរាប់ដើរចំរើនហ្វឹកហាត់ចិត្ត ឆ្ពោះទៅកាន់ទីរំលត់ទុក្ខ គឺ ព្រះនិព្វានបានតាមសេចក្តីប្រាថ្នារបស់លោកអ្នកប្រតិបត្តិ ។

តទៅនេះសូមលើកយក អរិយសច្ចទាំង ៤ ក្នុងវគ្គទី ៥ នៃវិបស្សនាភូមិ មកអធិប្បាយបំភ្លឺដល់លោកអ្នកប្រតិបត្តិវិបស្សនា កម្មដ្ឋានទាំងឡាយ ជាជំនួយគំនិតប្រាជ្ញា ក្នុងការសិក្សាព្រះបរមត្ថធម៌ ដូចន័យតទៅនេះ :

*អរិយសច្ច ទាំង ៤ គឺ* ទុក្ខ ១, ទុក្ខសមុទយ ១, ទុក្ខនិរោធ ១, ទុក្ខនិរោធគាមិនីបដិបទា ១, មាននាមមួយទៀត ហៅថា សាមុក្កំសិកធម៌ បានជាមានឈ្មោះដូច្នេះព្រោះជាធម៌ដែលព្រះសម្ពុទ្ធ ទ្រង់លើកឡើងសំដែងផ្ទាល់ដោយព្រះអង្គឯងជាមុន ហើយទើបជនឯទៀត ដែលបានស្តាប់អាច

សំដែងត១ ទៅទៀតបាន ។ ទាំងព្រះពុទ្ធជាម្ចាស់ ដែលបានព្រះនាមថាសម្មាសម្ពុទ្ធ ក៏មកពីព្រះអង្គមានសម្មាសម្ពោធិញ្ញាណសំរាប់ត្រាស់ដឹងនូវធម៌នេះ ។ ពួកសត្វដែលបានទទួលស្គាល់នូវព្រះអង្គថា សម្មាសម្ពុទ្ធ ក៏ទ្រង់បានប្រកាសព្រះធម្មចក្កគឺសំដែង អរិយសច្ចនេះឯង ដូចមនុស្សនិករ ដែលទទួលស្គាល់ព្រះមហាក្សត្រអង្គណាមួយ ថាជាចក្រពត្រាធិរាជ ដោយបានឃើញចក្ករតនៈ(ចក្រកែវ) ដែលកើតប្រាកដឡើងដល់ព្រះមហាតាមពិតដែរ ដែលមាន បរិវដ្ដៈ ៣ មានអាការៈ ១២ ក្នុងអរិយសច្ចទាំង ៤ នេះទេ នោះតថាគត ពុំបានប្ដេជ្ញាខ្លួនថាជាព្រះសម្មាសម្ពុទ្ធឡើយ ។

សេចក្ដីពណ៌នាមកហើយនេះ បញ្ជាក់ឱ្យឃើញថា អរិយសច្ច ទាំង ៤ នេះជាធម៌ មានគម្ភីរភាពជ្រាលជ្រៅ ហើយមានសេចក្ដីពិតឥតប្រែប្រួល ទាំងញាណទស្សនៈក្នុងធម៌នេះ ក៏ជាគម្ភីរញ្ញាណ អាចញ៉ាំងបុគ្គលឱ្យបានជាព្រះអរិយៈ គឺបានត្រាស់ជាព្រះពុទ្ធ ជាព្រះបច្ចេកពុទ្ធ និងជាព្រះអនុពុទ្ធ ។

បើញាណទស្សនៈនេះនៅទន់ខ្សោយ កំឱ្យបានត្រៃសរណគមន៍ជាលោកិយដែរ ។ ព្រោះ ត្រៃសរណៈគមន៍ ទាំងជាលោកិយទាំងជាលោកុត្តរៈ សុទ្ធតែជា ចិត្តុប្បាទ ប្រកបដោយសទ្ធានិងបញ្ញា ដែលជាអង្គគ្រឿងផ្សំឡើង ដូចគ្នា ។

សទ្ធានេះ បានដល់តថាគតពោធិសទ្ធា ជឿប្រាជ្ញាគ្រឿងត្រាស់ដឹងរបស់ព្រះពុទ្ធ ដ្បិតសទ្ធានេះ មានបញ្ញាជាមូល ។ បញ្ញានេះ គឺចតុសច្ចញ្ញាណ ដឹងតាមពិតក្នុងអរិយសច្ចទាំង ៤ ដែល ព្រះពុទ្ធទ្រង់សំដែងនោះឯង ហើយជាប្រទីបបំភ្លឺឱ្យឃើញតម្លៃពោធិញ្ញាណរបស់ព្រះពុទ្ធ នាំឱ្យមានសទ្ធាជឿជ្រះថ្លាក្នុងព្រះអង្គ ។ ព្រោះហេតុនោះ ពួកពុទ្ធបរិស័ទ ប្រកាសខ្លួនជាឧបាសក ឧបាសិកា ចំពោះព្រះរតនត្រ័យ ថាខ្លួនដល់នូវព្រះពុទ្ធព្រះធម៌ និង ព្រះសង្ឃ ជាទីពឹងទីរលឹកដរាបអស់ជីវិត ។

ក្នុងពុទ្ធសម័យ លោកអ្នកដែលបានប្រកាសខ្លួនជាឧបាសក ឧបាសិកា ដូចនាងសុជាតាព្រមទាំងស្វាមីជាដើមសុទ្ធតែបានស្តាប់ សាមុក្កំសិកធម៌ កើតប្រាជ្ញាយល់ច្បាស់

ក្នុងអរិយសច្ចនេះរួចមកហើយ មិនមែនគ្រាន់តែបានជួប ព្រះភក្ត្រព្រះអង្គ ហើយប្រកាសខ្លួនបែបនោះទេ ។ ហេតុនេះហើយទើបព្រះពុទ្ធជាម្ចាស់ ទ្រង់យកព្រះទ័យទុកដាក់ណាស់ ក្នុងការប្រកាសសាមុក្កង្សិកធម៌ (អរិយសច្ច) ដោយព្រះអង្គឯងផង បញ្ជូនពួកសាវ័កឱ្យទៅ ប្រកាសក្នុងទីនានាផង ដើម្បីឱ្យវេនេយ្យសត្វ ស្គាល់នូវគុណ ព្រះរតនត្រ័យដល់នូវសរណគមណ៍ បានមគ្គផលប្រតិស្ឋាន ក្នុង ផ្លូវសួគ៌និព្វាន ។ តាមបុណ្យវាសនាបារមី ដែលបុគ្គលនោះ ៗ បានសាងសន្សំទុកមកពីខាងដើមច្រើន ឬតិច ក្នុងការចំរើន វិបស្សនាភាវនា មានប្រាជ្ញាបរិបូណ៌ អាចយល់ដឹងឃើញច្បាស់ នូវអរិយសច្ចទាំង៤ នេះបានដោយប្រពៃ ។

លំដាប់ពីនេះ នឹងពណ៌នា នូវសាមុក្កង្សិកធម៌ គឺអរិយសច្ចទាំង ៤ នោះ ដោយសេចក្តីសង្ខេប ។

# ទី ១ គឺទុក្ខ

អ្វីជាទុក្ខ ? សង្ខារទាំងពួងជាទុក្ខ ។ អ្វីជាសង្ខារ ? បញ្ចក្ខន្ធ (ខន្ធ ៥ ) គឺរូប ១ វេទនា ១ សញ្ញា ១ សង្ខារ ១ វិញ្ញាណ ១ នេះជាសង្ខារ ។ ព្រោះអាស្រ័យហេតុអ្វីទើបជាសង្ខារ ? ព្រោះអាស្រ័យគ្រឿងផ្សំ គឺ ដី ទឹក ភ្លើង ខ្យល់ អាកាស និងវិញ្ញាណប្រមូលផ្តុំគ្នាឡើង ។

សង្ខារនេះ នឹងហៅថា នាមរូប ថាអាយតនៈ ថាធាតុ ថាឥន្ទ្រិយ ថាសច្ចៈ ថាបច្ចយាការៈ ដូច្នេះក៏បាន ។ ការហៅបែបនេះ គឺហៅតាម បរមត្ថវោហារ សម្រាប់បំភ្លឺឱ្យឃើញតាមពិតថា ក្នុងពួកមនុស្ស ឬទេវតាជាដើមនេះ គ្មានអ្វីដទៃ ចាកសង្ខារ គឺនាមរូប ឬខន្ធ ៥ ជាដើមនោះឡើយ គឺគ្រាន់តែជា សង្ខារ ជានាមរូប ជាខន្ធ ៥ ជាដើមដូចៗគ្នាទាំងអស់ ដែលហៅ តាមលោកវោហារ ថាមនុស្ស ថាទេវតាជាដើម គឺហៅតាមប្រភេទខ្ពង់ខ្ពស់ ថោកទាប ប្លែកគ្នាដែលកម្មបែងចែកឱ្យ ។ តែដែលពិត គឺគ្រាន់តែជា ដី

ទឹក ភ្លើង ខ្យល់អាកាស និងវិញ្ញាណប៉ុណ្ណោះ ។ សង្ខារដែលជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង យើងមាន កម្មជារបស់ខ្លួន ជាអ្នកទទួលផល នៃកម្ម មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទី ពំនាក់អាស្រ័យ យើងនឹងធ្វើនូវកម្មណាដែលជាបុណ្យ ឬជាបាប យើងនឹងជាអ្នក ទទួល នូវផលនៃកម្មនោះ ។

ពាក្យថាយើង ក្នុងពុទ្ធដីកានេះ ជាលោកវោហារ គ្រាន់តែជាអារម្មណ៍ នៃសមថភាវនា សម្រាប់ពិចារណាចាត់សេចក្ដីស្រវឹងក្នុងវ័យគឺភ្លេចចាស់ ក្នុងភាពមិនមានរោគគឺភ្លេចឈឺ ក្នុងជីវិត គឺភ្លេចស្លាប់ នឹងសម្រាប់ពិចារណា កំចាត់អភិសង្គៈ (ការជំពាក់ ចិត្ត ) ក្នុងសត្វនិងសង្ខារ ដែលជាចំណងក ចំណងដៃ ចំណងជើង ជាដើម ហើយម្ទីម្នាលះអំពើបាប ធ្វើតែនូវអំពើបុណ្យ ឱ្យបានទាន់ មិនខ្លួនចាស់ឈឺស្លាប់នោះ ៗ ប៉ុណ្ណោះ មិនបានជាអារម្មណ៍នៃ វិបស្សនាភាវនាទេ ។ បើប្រាថ្នាឱ្យបានជាអារម្មណ៍នៃវិបស្សនាភាវនា នោះត្រូវពិចារណាត្រង់ពាក្យថា យើងចាស់ យើងឈឺ យើងស្លាប់

យើងមានការព្រាត់ប្រាស យើងមានកម្មជារបស់ខ្លួននេះ តើអ្វីទៅជាយើង ? ការពិចារណាដូច្នេះ គង់នឹងឃើញ ការពិតថា គ្មានអ្វីជាយើងទេ អត្តភាពនេះគ្រាន់តែជាសភាវធម៌ គឺជានាមរូប ឬជាខន្ធ៥ ប៉ុណ្ណោះ ។ សភាវធម៌នេះឯងវាចាស់ វាឈឺ វាស្លាប់ វាព្រាត់ប្រាស វាប្រព្រឹត្តទៅតាមអំពើរបស់វាតែប៉ុណ្ណោះ ។ ក៏ទៅជាបរមត្ថវោហារយល់ត្រូវបានដល់ប្រាជ្ញាដែលឃើញនូវ សេចក្ដីទុក្ខ ១, ឃើញនូវហេតុដែលនាំឱ្យកើតសេចក្ដីទុក្ខ ១, ឃើញនូវទីរំលត់ទុក្ខ ១, ឃើញផ្លូវបដិបត្តិឱ្យដល់ ទីរំលត់ទុក្ខ ១, គឺឃើញអរិយសច្ច ៤ យ៉ាងនេះឯង ។

២. សម្មាសង្កប្បៈ តិរិះប្រពៃ ការត្រិះរិះប្រពៃ ការត្រិះរិះត្រូវ បានដល់ការត្រិះរិះដើម្បីផុតចាកកាម ១, ដើម្បីមិនព្យាបាទ ១, ដើម្បីមិនបៀតបៀន ១ ។

៣. សម្មាវាចា វាចាប្រពៃ វាចាដ៏ត្រឹមត្រូវ បានដល់ចេតនា ដែលនាំឱ្យវៀរចាកការនិយាយពាក្យមិនពិត ។

៤. សម្មាកម្មន្តៈ ការងារប្រពៃ ការងារត្រូវ បានដល់ចេតនា ដែលនាំឱ្យវៀរចាកការសម្លាប់សត្វ ១, វៀរចាកការលួចលាក់បំបាត់ទ្រព្យគេ ១, វៀរចាកការសេពន្ធូវមេថុនធម៌ ១ ។ ក្នុងមហាសតិប្បដ្ឋានសូត្រថា វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

៥. សម្មាអាជីវៈ ការចិញ្ចឹមជីវិតប្រពៃ ការចិញ្ចឹមជីវិតប្រកបដោយធម៌ ការចិញ្ចឹមជីវិតប្រាសចាកទោស បានដល់ចេតនាដែលនាំឱ្យប្រកបរបរប្រាសចាកការបៀតបៀនអ្នកដទៃ ។

៦. សម្មាវាយាមៈ ការព្យាយាមប្រពៃ ការព្យាយាមត្រូវបានដល់ការព្យាយាមមិនឱ្យសេចក្តីអាក្រក់ គឺអកុសលធម៌ដ៏លាមក កើតឡើងបាន ១, ព្យាយាមលះបង់សេចក្តីអាក្រក់ដែល កើតឡើងហើយ ១, ព្យាយាមញ៉ាំងសេចក្តីល្អ គឺកុសលធម៌ (ធ្វើអំពើល្អ) ដែលមិនទាន់កើត ឱ្យកើតឡើង ១, ព្យាយាមញ៉ាំង សេចក្តីល្អ ព្យាយាមធ្វើសេចក្តីល្អ

ព្យាយាមរក្សាសេចក្តីល្អ ដែលកើតមានហើយ ឱ្យរឹតតែកើតឡើងទៀត ត្រាតែពេញបរិបូណ៌ ភិយ្យោភាព ១ ។

៧. សម្មាសតិ ការរលឹកប្រពៃ ការរលឹកត្រូវ បានដល់ការពិចារណាឱ្យរឿយៗថា គ្រាន់តែជាកាយ ក្នុងកាយ មានពិចារណាក្នុងកាយសង្ខារ (គឺខ្យល់ដកដង្ហើមចេញចូល )១, ពិចារណារលឹករឿយៗ ក្នុងវេទនាគ្រាន់តែជាវេទនា ក្នុងវេទនា (ការទទួលនូវអារម្មណ៍សោយនូវអារម្មណ៍)ប៉ុណ្ណោះ, ពិចារណាឱ្យដឹង រឿយៗនូវចិត្ត (ការនឹកគិតទៅកាន់អារម្មណ៍) ថាគ្រាន់តែជាចិត្តប៉ុណ្ណោះ, ពិចារណានូវធម៌ក្នុងធម៌ ( គឺធម្មារម្មណ៍សភាវៈ នៃអារម្មណ៍ដែលមកប៉ះទង្គិចតាមផ្លូវចិត្ត ) គឺពិចារណាដោយ មានសតិសម្បជញ្ញៈ និងយោនិសោមនសិការៈប្រកបដោយប្រាជ្ញា កំចាត់ចេញនូវអភិជ្ឈា និងទោមនស្សក្នុងលោក ។

៨. សម្មាសមាធិ ការតាំងចិត្តប្រពៃ បានដល់ការតាំងចិត្តមូលក្នុងអារម្មណ៍តែមួយ ឱ្យបានស្ងាត់ចាកកាម នឹងចាកបាបអកុសលធម៌ ក្នុងមួយខណៈ ៗ ក្តី ដែលយើងកំពុងហ៊ឹកហាត់ ការ

ហ្វឹកហាត់ចិត្តឱ្យជំនាញក្នុងអារម្មណ៍ ការធ្វើចិត្តឱ្យស្ងប់ក្នុងអារម្មណ៍តែមួយជាឯកគ្គតារម្មណ៍ ចាប់តាំងពីបឋមជ្ឈានមានការ ស្ងប់ចាកវិតក្កៈ និងវិចារៈដោយទុតិយជ្ឈានក្តីឱ្យបានស្ងប់ចាកបីតិ ដោយតតិយជ្ឈានក្តី ឱ្យបានស្ងប់ចាកសុខៈ គឺញុំាងចិត្ត ឱ្យប្រកបតែ ដោយឯកគ្គតា និងឧបេក្ខា ដោយចតុត្ថជ្ឈានក្តី ។

អង្គទាំង ៨ ប្រការនេះ អង្គទី ១ និងទី ២ ចាត់ចូលក្នុងបញ្ញាខន្ធ ។ អង្គទី ៣ ទី ៤ និងទី ៥ ចាត់ចូលក្នុងសីលខន្ធ ។ អង្គទី ៦ ទី ៧ និងទី ៨ ចាត់ចូលក្នុងសមាធិខន្ធ ។ មានលំដាប់ជាបញ្ញា សីលសមាធិ ខុសពីលំដាប់នៃប្រតិបត្តិ ត្រូវតែសាងសីលរួចសមាធិ និងបញ្ញា ជាលំដាប់គ្នា ទើបអាចបានលទ្ធផលដល់ទីបំផុត សមដោយព្រះបាលីថា សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ មានសីលជួយគាំទ្រហើយ ទើបសមាធិ មានផលច្រើន មានអានិសង្សច្រើន សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ

មហានិសង្សា មានសមាធិជួយគាំទ្រហើយ ទើបបញ្ញាមានផលច្រើន មានអានិសង្សច្រើន បញ្ញាភាវិតំ ចិត្តំ អាសវេហិ វិមុច្ចតិ មានបញ្ញាជួយគាំទ្រហើយ ទើបចិត្តរួចចាកអាសវៈទាំងឡាយ ដូច្នេះជាដើម ។

ឯអរិយមគ្គនេះត្រូវមានអង្គជាគ្រឿងផ្សំ គឺបញ្ញាបែបនេះជាគោលឬជាប្រធាន បើមិនដូច្នោះទេពុំអាចជាអរិយមគ្គឡើយ ។ ដូច្នេះដើម្បីឱ្យសមដល់ដំណើរនេះផង ដល់វេនេយ្យសត្វអ្នកស្តាប់ដែលមានសីល និងសមាធិ ស្រាប់ហើយផង ទើបគួរសំដែងអង្គដែលជាតួបញ្ញានេះមុន ព្រោះវេនេយ្យសត្វពួកនេះ អាចបានមគ្គផលជាលោកុត្តរៈ តាំងពីបានស្តាប់ត្រង់អង្គខាងដើម មិនបាច់ចាំចប់ព្រះធម្មទេសនាទេ ។

អរិយមគ្គនេះ ជាផ្លូវទៅកាន់ព្រះនិព្វាន ដែលជាទុក្ខនិរោធ ទីរលត់ទុក្ខដូច្នេះហើយ ទើបចាត់ជាទុក្ខនិរោធគាមិនីបដិទា គឺប្រតិបត្តិឱ្យដល់នូវទីរលត់ទុក្ខពិត ជាអរិយសច្ចទី ៤ ។

អរិយសច្ចទាំង៤នេះ អាចញុំាងជនដែលបានពិចារណាឃើញធម៌នេះ ឱ្យបានឡើងឋានៈខ្ពង់ខ្ពស់ជាព្រះអរិយជន គឺបានត្រាស់ដឹងជាព្រះពុទ្ធ ជាព្រះបច្ចេកពុទ្ធ និងជាអគ្គសាវកពុទ្ធជាដើម ។ បើមិនដល់ទៅម្ល៉ោះ ក៏គង់ឱ្យបានឡើងឋានៈជាកល្យាណបុថុជ្ជន ដែលមានសរណគមន៍ មានសីលបរិសុទ្ធ ល្មមជាអ្នកមានខ្លួនជាទីពឹង ជាទីកក់ក្ដៅនៃខ្លួនបាន ។ ហើយធម៌នេះមាននៅតែក្នុងអត្តភាព គឺខន្ធនេះជាធម្មតា គឺថាទុក្ខក៏មាន ហេតុនៃទុក្ខក៏មាន ទីរលត់ទុក្ខក៏មាន ផ្លូវជាទីទៅកាន់ទីរលត់ទុក្ខក៏មាន តែដោយគ្មានអ្នកស្គាល់ក៏ប្រាកដដូចជាពុំមាន ។ លុះព្រះពុទ្ធបានត្រាស់ដឹងឡើង ទើបទាញខន្ធ ដែលសន្មតថាជាអត្តភាពនេះមកបង្ហាញឱ្យវេនេយ្យ សត្វពិចារណាថា នេះជាទុក្ខសច្ច គប្បីកំណត់ដឹងព្រោះជាទុក្ខពិត។ នេះជាទុក្ខសមុទយសច្ចគប្បីលះ ព្រោះជាហេតុនៃទុក្ខពិត។ នេះជាទុក្ខនិរោធសច្ច គប្បីធ្វើឱ្យជាក់ច្បាស់ព្រោះជាទីរលត់ទុក្ខពិត ។

នេះជាមគ្គសច្ច គប្បីចំរើន ព្រោះជាផ្លូវរលត់ទុក្ខពិត ។ ហើយ ព្រះអង្គឯង ក៏ទ្រង់កំណត់ដឹងនូវទុក្ខ លះនូវសមុទ័យ ធ្វើនិរោធឱ្យ ជាក់ច្បាស់ ចំរើនមគ្គដែលជាករណីយកិច្ច ៤ ៗ ក្នុងមគ្គទាំង ៤ មានសោតាបត្តិមគ្គជាដើម រួចស្រេចទៅហើយ ។

សេចក្តីនេះធ្វើឱ្យឃើញថាអរិយសច្ចចំពោះព្រះភិក្ខុសង្ឃថា :

ចតុន្នំ អរិយសច្ចានំ យថាភូតំ អទស្សនា សំសរិតំ ទីឃមទ្ធានំ តាសុ តាស្វេវ ជាតិសុ ។

សង្សារគឺការរង្គាត់ទៅ អស់កាលជាយូរអង្វែង ក្នុងជាតិនោះ ៗ ឯងព្រោះមកពីពុំមានទស្សនៈ ឃើញតាមពិតនូវអរិយសច្ចទាំង ៤ ។

ក្នុងព្រះពុទ្ធដីកានេះ មានន័យថា តថាគតក្តី អ្នកទាំងឡាយក្តី ដែលចេះតែរង្គាត់កើតចាស់ឈឺស្លាប់ ហើយព្រាត់ប្រាសចាកសត្វ និងសង្ខារដែលជាទីស្រឡាញ់ ជាទីគាប់ចិត្ត មិនចេះអស់ មិនចេះហើយនោះ មកពីយើងមិនទាន់ឃើញអរិយសច្ចទាំង ៤ នេះឯង

ឥឡូវយើងបានឃើញហើយ យើងនឹងផុតទុក្ខទាំងនេះពុំខាន ឡើយ ។

ហេតុនេះហើយ អរិយសច្ចទាំង៤នេះ ទើបជាធម៌គួរដែលយើងគប្បីរៀន គប្បីស្តាប់ គប្បីពិចារណា ឱ្យកើតប្រាជ្ញាជាសម្មាទិដ្ឋិ ដែលជាអង្គអរិយមគ្គ ។ ព្រោះប្រាជ្ញានេះជានិយ្យានិកធម៌យ៉ាងឯកអាចជួយស្រោចស្រង់ យើងឱ្យជាអ្នកមានសរណគមន៍ និងមានទាន សីល ភាវនា យ៉ាងបរិសុទ្ធបាន ។

## ឧសំនួរនិងចម្លើយបញ្ចប់

តណ្ហាដែលជាហេតុនៃទុក្ខ ជាទុក្ខដែរឬ ? ជាទុក្ខដែរ គឺជាទុក្ខផង ជាមូលនៃទុក្ខផង មិនមែនជាទុក្ខត្រឹមតែខន្ធ ៥ ដែលជាផល ប៉ុណ្ណោះទេ ។ ដូចលោភៈ ទោសៈ និងមោហៈ ដែលជាអកុសល នឹងជាអកុសលមួយដែរ ។ ធម្មតាឈើស្រោយ មិនមែនស្រោយ តែដើមនិងមែកទេ សូម្បីឫសគល់វាក៏ស្រោយដែរ ។

ចុះតណ្ហានេះ មានអ្វីជាមូល ? មានអវិជ្ជាជាមូល ។ កាលបើអវិជ្ជា ជាមូលនៃតណ្ហាហើយ វិជ្ជាក៏ជាមូលនៃនិព្វានដែរ ។ រឿងនេះឱ្យន័យទៅក្នុងអរិយសច្ចទាំង ៤ ថា តណ្ហាជាទុក្ខ ។ ការមិនស្គាល់ទុក្ខ ជាសមុទ័យ ។ ការស្គាល់ទុក្ខ ជាមគ្គ ។ ដោយសារមគ្គ ទុក្ខក៏រលត់ នេះជានិរោធ ។

ឥមិនា ធម្មទានេន ធម្មស្ស បូជនេន ច

វុឌ្ឍិ វិរុឡ្ហិ បប្បោតុ សន្តិភាវញ្ច កម្ពុជា

ដោយធម្មទាននេះក្តី ដោយធម្មបូជា គឺប្រតិបត្តិតាមធម៌នេះក្តី សូមប្រទេសកម្ពុជា ជួបប្រសព្វ នៃការលូតលាស់ចំរើន ព្រម ទាំងនូវសន្តិភាព គ្រប់កាល

ចប់

( ពិនិត្យដោយ : ព្រះគ្រូធម្មាចារ្យ យូ យ៉ែម យាទិកត្ថេរ. រៀបរៀងដោយ : ព្រះភិក្ខុ យូ ប៊ុនរី បុណ្ណធម្មោ. លោក ហាស់ ម៉េងហួត )

សុខោបុញ្ញស្សឧច្ចយោ

ការសន្សំបុណ្យនាំមកនូវសេចក្តីសុខ

ព្រះពុទ្ធជាម្ចាស់ទ្រង់បានទូន្មានថា

នត្ថិ សន្តិ បរំ សុខំ ពុំមានសេចក្តីសុខ

ដទៃក្រៅអំពីសេចក្តីស្ងប់ឡើយ



ប្រាសាទនាគព័ន្ធ